**អង្គការសហប្រជាជាតិ** **E**

ការចែកចាយទូទៅ

**ក្រុមប្រឹក្សាសេដ្ឋកិច្ច**
**និង សង្គមកិច្ច**

E/CN.4/2004/104
ថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០០៤
អត្ថបទដើម: អង់គ្លេស

គណៈកម្មាធិការសិទ្ធិមនុស្ស
សម័យប្រជុំលើកទី ៦០
ចំណុចទី ១៩ នៃរបៀបវារៈបណ្ដោះអាសន្ន

# សេវាប្រឹក្សាយោបល់ និង សហប្រតិបត្តិការបច្ចេកទេស ក្នុងវិស័យសិទ្ធិមនុស្ស

## តួនាទី និង លទ្ធផលរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកស្ទួយ និង ការការពារសិទ្ធិមនុស្ស

របាយការណ៍របស់លោកអគ្គលេខាធិការ

# សេចក្តីសង្ខេប

របាយការណ៍នេះ រៀបរាប់អំពីតួនាទី និង លទ្ធផលទទួលបានរបស់ការិយាល័យឧត្តមស្នងការ អ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR/Cambodia) ចាប់ពី ខែកក្កដា ដល់ ខែធ្នូ ឆ្នាំ ២០០៣ ក្នុងការជួយដល់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស ។ របាយការណ៍នេះបានរៀបចំឡើង ដោយអនុលោមតាមសេចក្តីសំរេចចិត្តលេខ ២០០៣/៧៩ ដែលអនុម័ត ដោយគណៈកម្មាធិការសិទ្ធិមនុស្ស កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៣ ។

នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបានបន្តជួយគាំទ្រដល់តំណាងពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្នុងការបំពេញតួនាទីភារកិច្ច និងបានជួយសំរួលដល់បេសកកម្មលើកទី១០ របស់លោកមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី ២៧ ខែ វិច្ឆិកា មកទល់នឹងថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ២០០៣ ។

ការសិក្សាវាយតំលៃដោយក្រុមជំនាញពីខាងក្រៅ អំពីការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានធ្វើឡើងកាលពីចុងខែតុលា និងដើម ខែវិច្ឆិកា ឆ្នាំ ២០០៣ ដើម្បីធ្វើការប៉ាន់ប្រមាណពីផលប៉ះពាល់ និងសារៈសំខាន់នៃកម្មវិធីរបស់ការិយាល័យ បញ្ហាចម្បងៗ ទាក់ទងនឹងការការពារនិងការលើកស្ទួយសិទ្ធិមនុស្ស ភាពជឿនលឿនទៅមុខ ដែលអាចកើតឡើង ពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាពេលថ្មីៗនេះ និងការបំពេញបន្ថែមនៅក្នុងកម្មវិធី របស់ការិយាល័យនូវសកម្មភាពផ្សេងៗទៀត ដែលទាក់ទងទៅនឹងសកម្មភាពរបស់អង្គការសហប្រជាជាតិ ។ បេសកកម្មវាយតំលៃនេះ បានលើកឡើងជាអនុសាសន៍មួយចំនួនស្តីពីតួនាទី និងរចនាសម្ព័ន្ធរបស់ការិយាល័យសំរាប់ថ្ងៃអានាគត ។ បេសកកម្មនេះបានធ្វើសេចក្តីសន្និដ្ឋានថា វត្តមាននៃការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា តំណាងអោយការប្តេជ្ញាចិត្តជាវិជ្ជមានមួយ របស់សហគមន៍អន្តរជាតិ ចំពោះប្រទេសកម្ពុជា និងថាការបន្តមានវត្តមាននៃការិយាល័យប្រចាំកម្ពុជា គឺមានសារៈសំខាន់ជាទីបំផុតសំរាប់ការលើកស្ទួយអោយមានការគោរពសិទ្ធិមនុស្ស រហូតដល់មានការកែប្រែស្ថានភាពសិទ្ធិមនុស្សដល់កំរិតមួយ ដែលគួរជាទីពេញចិត្ត និងរង់ចាំការបង្កើតអោយមានស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិមួយដែលឯករាជ្យ និង មានប្រសិទ្ធិភាព ។ នៅពេលដែលមានវិស័យខ្លះតម្រូវឱ្យមាន

ការផ្តោតការយកចិត្តទុកដាក់ និងកែលំអរបន្ថែមទៀតនោះ គេពិនិត្យឃើញថាកម្មវិធីរបស់ការិយាល័យបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកស្ទួយដល់សិទ្ធិមនុស្ស ជាពិសេសក្នុងវិស័យការពារសិទ្ធិមនុស្ស ។

ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការអនុវត្តន៍អោយបានសំរេច នូវកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្សទូទៅ ស៊ើបអង្កេតរបាយការណ៍ស្តីពីការរំលោភសិទ្ធិមនុស្ស និងចងក្រងជាឯកសារអំពីគំរូនៃករណីរំលោភទាំងនេះ ។ ការិយាល័យក៏បានលើកឡើងជាប្រចាំអំពីការព្រួយបារម្ភរបស់ខ្លួនជំរាបដល់អាជ្ញាធរថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់ខេត្ត ដើម្បីស្នើសុំអោយជួយធ្វើអន្តរាគមន៍ ។

កម្មវិធីសកម្មភាពនៃការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ រួមមាន : ការងារការពារនៅក្នុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត និងក្នុងរយៈពេលប៉ុន្មានខែក្រោយពេលបោះឆ្នោត ផ្តល់ពត៌មានដល់រដ្ឋាភិបាល និង សហគមន៍អន្តរជាតិស្តីពីស្ថាន-ការណ៍សិទ្ធិមនុស្ស ធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលឃ្លាំមើលបញ្ហាសិទ្ធិមនុស្សទាក់ទងនឹងការបោះឆ្នោត និងឆ្លើយតបចំពោះសេចក្តីព្រួយបារម្ភអំពីការការពារសុវត្ថិភាពរបស់គេ ហើយ និង ជួយក្នុងការរៀបចំធ្វើរបាយការណ៍សាធារណៈ ដែលចេញផ្សាយដោយលោកតំណាងពិសេស ហើយរបាយការណ៍ដែលថ្មីជាងគេបំផុតនោះ គឺត្រូវបានចេញផ្សាយកាលពីខែ ធ្នូ ឆ្នាំ ២០០៣។ កម្មវិធីស្តីពីការបោះឆ្នោត នឹងបិទនៅចុងខែមករា ឆ្នាំ២០០៤។

ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការបង្កើតគោលនយោបាយស្តីពីធនធានធម្មជាតិ អោយបានស្របនឹងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ប្រទេសកម្ពុជា ការិយាល័យបានផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពនៃគោលនយោបាយដីធ្លី ដែលក្នុងបញ្ហានេះការិយាល័យបានទទួលពត៌មានតិចតួចស្តួចស្តើងណាស់ស្តីពីដីកម្មសិទ្ធិសាធារណៈ ។ ការិយាល័យបានបន្តធ្វើការសិក្សាស្រាវជ្រាវ និងការវិភាគតាមរយៈការងារមូលដ្ឋានអំពីផលប៉ះពាល់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុង ឬជិតព្រំប្រទល់ដីដាំដុះកសិកម្មដែលមានទ្រង់ទ្រាយធំៗនិងអំពីវិសាលភាពដែលការដាំដុះកសិកម្មទ្រង់ទ្រាយធំៗទាំងនេះ បានរួមចំណែកចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សុខមាលភាពរបស់ប្រជាជនកម្ពុជាទាំងមូល ។ ផ្អែកតាមការរកឃើញ

តាមរយៈការសិក្សាស្រាវជ្រាវនេះ ការិយាល័យនិងលើកឡើងជាអនុសាសន៍ជូនដល់អាជ្ញាធររបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ និងជូនដល់ទីភ្នាក់ងារអន្តរជាតិនានា ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តរួមចំណែកដល់កិច្ចដំណើរការធ្វើច្បាប់ និង កិច្ចដំណើរការកំណែទម្រង់ផ្នែកយុត្តិធម៌ តាមរយៈការផ្តល់មតិលើសេចក្តីព្រាងច្បាប់ ធានាសម្របសម្រួលអោយមានការពិភាក្សាគ្នា រវាងភាគីដែលមានផលប្រយោជន៍ ស្តីពីបញ្ហាគោលនយោបាយច្បាប់ ផ្តល់យោបល់លើបញ្ហាច្បាប់ ជាពិសេសលើកិច្ចដំណើរការ និង នីតិវិធីព្រហ្មទណ្ឌ និង សង្កេតការសវនាការជំនុំជំរះក្តីនៅក្នុងប្រព័ន្ធតុលាការ ក្នុងករណីរឿងដែលមានការព្រួយបារម្ភ ។ ការិយាល័យបានបន្តការងាររបស់ខ្លួនស្តីពីគំរោងមេធាវីការពារជនក្រីក្រ តាមរយៈការសិក្សាស្រាវជ្រាវអំពីបញ្ហាមេធាវីតំណាងនៅក្នុងរឿងក្តីនានា ។ ការិយាល័យបានប្រមូលទិន្នន័យនៅតុលាការចំនួនបួន ហើយបានពិគ្រោះយោបល់ជាមួយអង្គការនានា ដែលផ្តល់នូវគំរោងមេធាវីការពារជនក្រីក្រនៅក្នុងប្រទេសកម្ពុជា ដើម្បីរៀបចំឯកសារជំហានដំបូងមួយស្តីពីសិទ្ធិក្នុងការដោះស្រាយរឿងក្តីតាមផ្លូវតុលាការសំរាប់ជនក្រីក្រ ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបានបន្តគាំទ្រ និង សហការយ៉ាងជិតស្និទ្ធិជាមួយអង្គការក្រៅរដ្ឋាភិបាល និង សង្គមស៊ីវិលនានា ក្នុងការអនុវត្តការងាររបស់ខ្លួន ស្របតាមសេចក្តីប្រកាសស្តីពីសិទ្ធិ និង ការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គម ដើម្បីលើកស្ទួយ និង ការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល ។ ការិយាល័យក៏បានចូលរួមយ៉ាងសកម្មផងដែរ ក្នុងការអនុវត្តជំនួយបច្ចេកទេស និង ការអប់រំ ហើយនិងកម្មវិធីសេវាប្រឹក្សាយោបល់ ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តការងាររបស់ខ្លួនលើសិទ្ធិខាងសេដ្ឋកិច្ច និង សង្គមកិច្ច ។ ដោយសារតែមានចំណងទាក់ទងយ៉ាងជិតស្និទ្ធគ្នារវាងសុខភាព និងភាពក្រីក្រនោះ ការិយាល័យប្រចាំកម្ពុជាក៏បានចាប់ផ្តើមធ្វើការពិគ្រោះយោបល់ និងសិក្សាស្រាវជ្រាវអំពីសិទ្ធិខាងសុខភាព ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តចូលនៅក្នុងយន្តការសម្របសម្រួលនៃអង្គការសហប្រជាជាតិ និងបណ្តាប្រទេសអ្នកផ្តល់ជំនួយ និងនៅក្នុងសកម្មភាពផ្សេងៗ និងក្នុងអង្គប្រជុំនៃក្រុមទីភ្នាក់អង្គការសហប្រជាជាតិប្រចាំប្រទេស ក្នុងទិសដៅដើម្បីដាក់បញ្ចូលសិទ្ធិមនុស្សទៅក្នុងកិច្ចដំណើរការការអភិវឌ្ឍន៍ជាតិ ដែលរួមមានយុទ្ធសាស្រ្តក្នុងការកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ គោលដៅអភិវឌ្ឍន៍សហស្សវត្ស ហើយនិងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ។

# មាតិកា


| | កថាខ័ណ្ឌ | ទំព័រ |
|---|---|---|
| សេចក្តីផ្តើម | ១-៦ | ៦ |
| I- ការជួយដល់តំណាងពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប | ៧-៨ | ១០ |
| II- តួនាទីរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកស្ទួយ និង ការការពារសិទ្ធិមនុស្ស | ៩-៥៥ | ១១ |
| ក. ទិសដៅទូទៅ | ៩-១០ | ១១ |
| ខ. បេសកកម្មនៃក្រុមសិក្សាស្រាវជ្រាវវាយតំលៃ | ១១-១៤ | ១២ |
| គ. ការការពារសិទ្ធិមនុស្ស ការឃ្លាំមើល ការស៊ើបអង្កេត និងការធ្វើសេចក្តីរាយការណ៍ | ១៥-១៧ | ១៦ |
| ឃ. កម្មវិធីបោះឆ្នោត | ១៨-២០ | ១៧ |
| ង. ការសិក្សាស្រាវជ្រាវអំពីបញ្ហានិទណ្ឌភាព | ២១ | ១៨ |
| ច. គំរោងកម្មវិធីផ្នែកដីធ្លី | ២២-២៧ | ១៩ |
| ឆ. សិទ្ធិមនុស្សក្នុងការអភិវឌ្ឍន៍ រួមទាំងសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ២៨-៣១ | ២១ |

| | | |
|---|---|---|
| ជ. ក្របខ័ណ្ឌនៃនីតិរដ្ឋ | ៣២-៤១ | ២២ |
| ឈ. ការិយាល័យប្រចាំតំបន់ក្នុងខេត្តបាត់ដំបង | ៤២-៤៤ | ២៧ |
| ញ. កាតព្វកិច្ចក្នុងការធ្វើរបាយការណ៍ស្តីពីសិទ្ធិមនុស្ស និង ការអនុវត្ត អនុសាសន៍ធ្វើឡើងដោយស្ថាប័នសំរាប់ត្រួតពិនិត្យការអនុវត្តសន្ធិសញ្ញា | ៤៥-៤៧ | ២៨ |
| ដ. ជំនួយផ្នែកអប់រំ និងបច្ចេកទេស និង កម្មវិធីពត៌មានសាធារណៈ | ៤៨-៥២ | ៣០ |
| ឋ. សហប្រតិបត្តិការ និងការសម្របសំរួលជាមួយប្រព័ន្ធអង្គការសហប្រជាជាតិ ប្រទេសអ្នកផ្តល់ជំនួយ និងសហគមន៍អ្នកការទូត | ៥៣-៥៥ | ៣១ |
| III- បុគ្គលិកការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និង ស្ថានភាពហិរញ្ញវត្ថុនៃមូលនិធិឧបត្ថម្ភដោយស្ម័គ្រចិត្តរបស់អង្គការ សហប្រជាជាតិសំរាប់កម្មវិធីអប់រំសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា | ៥៦-៦២ | ៣២ |

# សេចក្តីផ្តើម

១. ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR/Cambodia) ត្រូវបាន បង្កើតឡើងដោយអនុលោមតាមសេចក្តីសំរេចចិត្តលេខ ១៩៩៣/៦ របស់គណៈកម្មាធិការសិទ្ធិមនុស្ស ដែលបានប្រគល់ឱ្យការិយាល័យបំពេញសកម្មភាពដូចតទៅ:

(ក) ចាត់ចែងគ្រប់គ្រងការអនុវត្តន៍ជំនួយឧបត្ថម្ភផ្នែកអប់រំបច្ចេកទេស កម្មវិធីសេវាប្រឹក្សាយោបល់ និងធានាអោយកម្មវិធីទាំងនេះបន្តនិរន្តរភាព ។

(ខ) ជួយដល់រដ្ឋាភិបាលកម្ពុជា តាមការស្នើសុំរបស់រដ្ឋាភិបាលនេះ ក្នុងការបំពេញកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនអោយបានសំរេច ស្របតាមលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិនានាដែលខ្លួនបានចូលជាភាគី រួមមានការរៀបចំធ្វើរបាយការណ៍ដាក់ជូនស្ថាប័នត្រួតពិនិត្យការអនុវត្តន៍សន្ធិសញ្ញាដែលពាក់ព័ន្ធ ។

(គ) ផ្តល់ការគាំទ្រដល់ក្រុមសិទ្ធិមនុស្សពិតប្រាកដ នៅក្នុងប្រទេសកម្ពុជា ។

(ឃ) រួមចំណែកក្នុងការបង្កើត និង/ឬពង្រឹងស្ថាប័នជាតិនានាដែលលើកស្ទួយ និងការពារសិទ្ធិមនុស្ស ។

(ង) បន្តជួយក្នុងការងារព្រាងច្បាប់ និងអនុវត្តច្បាប់ ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស ។

(ច) បន្តជួយហ្វឹកហ្វឺនដល់អ្នកដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ។

២. ការិយាល័យឧត្តមស្នងការ ក៏ជួយដល់តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ក្នុងការបំពេញការងាររបស់លោកតាមតួនាទីភារកិច្ច ដែលបានកំណត់ដោយសេចក្តីសំរេចចិត្តរបស់មហាសន្និបាត និង គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប ។

៣.	នៅក្នុងរបាយការណ៍នេះ មានពត៌មានស្តីពីតួនាទី និងលទ្ធផលទទួលបានរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ចាប់ពីខែកក្កដា ឆ្នាំ ២០០៣ ដល់ខែធ្នូ ឆ្នាំ ២០០៣ ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជាក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ។ របាយការណ៍បានរៀបចំឡើងស្របតាមសេចក្តីសំរេចចិត្តរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ២០០៣/៧៩ ដែលបានអនុម័ត កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៣ ។ ពត៌មានស្តីពីការងាររបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ចាប់ពី ខែ មករា ឆ្នាំ ២០០៣ ដល់ខែ មិថុនា ឆ្នាំ ២០០៣ មានចែងនៅក្នុងរបាយការណ៍ដាក់ជូនមហាសន្និបាតនាសម័យប្រជុំលើកទី ៥៨ (A/58/268) ។

៤.	អនុស្សរណៈនៃកិច្ចព្រមព្រៀងសំរាប់ការអនុវត្តន៏កម្មវិធីសហប្រតិបត្តិការបច្ចេកទេសស្តីពីសិទ្ធិមនុស្សដែលមានរយៈពេល ២ ឆ្នាំត្រូវបានចុះហត្ថលេខា ដោយលោកស្រីឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងរាជរដ្ឋាភិបាលកម្ពុជាកាលពីខែ កុម្ភៈ ឆ្នាំ ២០០២ ។ អនុស្សរណៈរួមមានវិស័យសហប្រតិបត្តិការដូចតទៅនេះ: ការផ្តល់ជំនួយបន្តដល់រដ្ឋាភិបាលក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ការជំរុញអោយមានការដាក់បញ្ចូលវិស័យសិទ្ធិមនុស្សអោយបានច្រើនថែមទៀត ទៅក្នុងកម្មវិធីអប់រំ សុខាភិបាល និងកម្មវិធីអភិវឌ្ឍន៏ដទៃទៀត ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដល់កម្មវិធីកំណែទម្រង់នានារបស់រដ្ឋាភិបាល ដែលរួមមានក្នុងវិស័យគ្រប់គ្រងយុត្តិធម៌ និងកិច្ចដំណើរការតាក់តែងច្បាប់ លើកទឹកចិត្តការចូលរួមរបស់សង្គមស៊ីវិល និងលើកតម្កើងការអប់រំជាសាធារណៈអំពីលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ជាពិសេសក្នុងវិស័យសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការផ្តល់តាមការស្នើសុំរបស់រដ្ឋាភិបាល នូវជំនួយបច្ចេកទេស និងយោបល់ក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួន រួមមានការដាក់ជូនរបាយការណ៍ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ។ នៅក្នុងអំឡុងពេលទស្សនៈកិច្ចលើកទី១០ របស់តំណាងពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិ-មនុស្សនៅកម្ពុជា លោកនាយករដ្ឋមន្ត្រីបានសន្យាថា នៅពេលដែលអនុស្សារណៈនៃកិច្ចប្រមព្រៀងបច្ចុប្បន្នត្រូវផុតកំណត់ រដ្ឋាភិបាលនឹងអោយបន្តអាណត្តិនៃអនុស្សារណៈនៃកិច្ចព្រមព្រៀងជាថ្មីឡើងវិញ ។

៥. ការិយាល័យអនុវត្តកម្មវិធីរបស់ខ្លួន ដោយសហការជាមួយស្ថាប័នមួយចំនួនដែលមានភារកិច្ចទទួលខុសត្រូវក្នុងវិស័យសិទ្ធិមនុស្ស រួមមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តុលាការ ការិយាល័យមហា-អយ្យការ សាលាភូមិន្ទបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញា គណៈកម្មការសិទ្ធិមនុស្ស និងទទួល

ពាក្យបណ្តឹង និងគណៈកម្មការនីតិកម្មនៃរដ្ឋសភា និងព្រឹទ្ធសភា គណៈកម្មាធិការសិទ្ធិមនុស្ស កម្ពុជា នាយកដ្ឋានពន្ធនាគារ និងក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រសួងសុខា- ភិបាល ។ ការិយាល័យក៏សហការជាមួយអង្គការក្រៅរដ្ឋាភិបាលជាច្រើន ដែលធ្វើការខាងវិស័យ សិទ្ធិមនុស្ស ច្បាប់ និង បញ្ហាអភិវឌ្ឍន៍ ។

៦.　　ការសិក្សាពិនិត្យវាយតំលៃឡើងវិញពីខាងក្រៅអំពីមុខងាររបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និងកម្មវិធីការងាររបស់ការិយាល័យនេះ បានធ្វើឡើងកាលពីខែតុលា ដល់ខែ វិច្ឆិកា ឆ្នាំ ២០០៣ កន្លងទៅនេះ មានគោលដៅធ្វើជាអនុសាសន៍មួយស្តីពីមុខងារ និងវច្ចនាសម្ព័ន្ធរបស់ការិយាល័យសំរាប់ថ្ងៃអានាគត ។

## I- ការជួយដល់តំណាងពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប

៧.　　នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានផ្តល់ពតិមានជាទៀងទាត់ជូនតំណាងពិសេសនៃលោកអគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ទាក់ទងនឹងបញ្ហានានាដែលគួរអោយព្រួយបារម្ភ ជាពិសេសក្នុងវិស័យ : កំណែទម្រង់ ផ្នែកយុត្តិធម៌ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ កាលពីខែកក្កដា ឆ្នាំ ២០០៣ ការរិតត្បិតលើសេរីភាព ក្នុងការសម្តែងមតិ ការបង្កើតសមាគម និងការរួមប្រជុំ ការប្រើកំលាំងហួសហេតុដោយនគរបាល បញ្ហាដទៃទៀតទាក់ទងនឹងអំពើពុករលួយ ការចំណាយ និង សិទ្ធិត្រូវដឹងពតិមាន បញ្ហាដីធ្លី និងព្រៃឈើ ស្ថានភាពពន្ធនាគារ និងកំណែទម្រង់ពន្ធនាគារ និទណ្ឌភាព ទំនាក់ទំនងរវាងតុលាការ និងនគរបាល គំរោងមេធាវីសំរាប់ការពារជនក្រីក្រ បញ្ហាជាច្រើនស្តីពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ការអភិវឌ្ឍន៍ដោយផ្អែកតាមគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន និង សិទ្ធិខាងសេដ្ឋកិច្ច និងសង្គមកិច្ច និងការគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ។

៨.　　ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានសំរួលដល់ដំណើរទស្សនៈកិច្ចលើកទី១០ របស់លោកតំណាងពិសេសមកកាន់ប្រទេសកម្ពុជា ដែលធ្វើឡើងស្របតាមតួនាទីភារកិច្ចរបស់លោក : ដើម្បីរក្សាទំនាក់ទំនងជាមួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា  ណែនាំ និង សម្របសំរួលវត្ត

មានការិយាល័យសិទ្ធិមនុស្ស អ.ស.ប នៅប្រទេសកម្ពុជា និងដើម្បីជួយដល់រដ្ឋាភិបាលក្នុងការ លើកស្ទួយ និងការពារសិទ្ធិមនុស្ស ។ ការរកឃើញនៅក្នុងពេលបំពេញបេសកកម្ម ដែលបានធ្វើឡើង ពីថ្ងៃទី២៧ ខែវិច្ឆិកា ដល់ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៣ ត្រូវបានសរសេរសង្ខេបនៅក្នុងរបាយការណ៍របស់លោកដាក់ជូនកម្មាធិការសិទ្ធិមនុស្ស ក្នុងសម័យប្រជុំលើកទី៦០ (E/CN.4/2004/105) និងនៅក្នុង របាយការណ៍លើកទី២ ដែលចេញដោយលោកតំណាងពិសេសស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ កាលពីពាក់កណ្តាលខែ ធ្នូ ឆ្នាំ ២០០៣ ។ បេសកកម្មរបស់លោកតំណាងពិសេស បានផ្តោតការយកចិត្តទុកដាក់លើបរិយាកាសនយោបាយទូទៅ នៅក្នុងពេលចាប់ផ្តើមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ កំណែទម្រង់ផ្នែកយុត្តិធម៌ បញ្ហានៅតែមានជាបន្តនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងផលប៉ះពាល់ដល់សិទ្ធិមនុស្ស ដោយសារគោលនយោបាយស្តីពីធនធានធម្មជាតិនៅប្រទេសកម្ពុជា និងការអនុវត្តន៍ ។ លោកបានបន្តពិភាក្សា និង លើកស្ទួយដល់ការអភិវឌ្ឍន៍ ដោយផ្អែកលើគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន ហើយនិងបានចាប់ផ្តើម ពិគ្រោះយោបល់ស្តីពីសិទ្ធិខាងសុខភាព ។ ការិយាល័យបានរៀបចំឯកសាររបាយការណ៍ពិស្តារជូនលោក តំណាងពិសេស ដើម្បីសម្រួលដល់បេសកកម្មរបស់លោក និងបានជួយលោកតំណាងពិសេសក្នុងការរៀប ចំរបាយការណ៍ដាក់ជូនមហាសន្និបាត និងគណៈកម្មាធិការសិទ្ធិមនុស្ស ហើយរបាយការណ៍ និងសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់លោកត្រូវបានចេញផ្សាយនៅក្នុងប្រទេសកម្ពុជា ។

## II- តួនាទីរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកស្ទួយ និង ការការពារសិទ្ធិមនុស្ស

### ក. ទិសដៅទូទៅ

៩. យុទ្ធសាស្ត្ររបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា គឺរួមបញ្ចូលគ្នានូវវិធីពីរទន្ទឹមគ្នា គឺធ្វើការលើកបញ្ហាដែលកើតឡើងភ្លាមៗ នៅក្នុងខណៈពេលដែលកំពុងអនុវត្តគោលដៅសំរាប់រយៈពេលវែងស្តីពីការជួយបង្កើត និងពង្រឹងស្ថាប័ននានា សំរាប់ថែរក្សាការពារ និងធានាការគោរពសិទ្ធិមនុស្សនៅក្នុងពេលអានាគត ។ ដោយធ្វើការរួមគ្នាជាមួយស្ថាប័នដទៃទៀត ការិយាល័យមានបំណង

រួមចំណែកក្នុងការធ្វើអោយទៅជាសង្គមកម្ពុជាមួយ ដែលយកការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន ស្របតាមនីតិរដ្ឋ និងដែលមានសង្គមស៊ីវិលមួយដ៏ខ្លាំង ដែលអាចដំណើរការការងារស្របតាមបញ្ញត្តិនៃសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គមនានា ដើម្បីលើកស្ទួយ និង ការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ជាសាកល ។

១០. ភារកិច្ចទាំងនោះរួមមានការកសាងប្រព័ន្ធតុលាការឯករាជ្យមួយ បង្កើតអោយមានការត្រួតពិនិត្យថ្លឹងថ្លែងអោយមានតុល្យភាពលើការអនុវត្តអំណាចនីតិប្រតិបត្តិ និងយន្តការនៃការទទួលខុសត្រូវដ៏មានប្រសិទ្ធិភាព និងប្រឆាំងបញ្ហានិទណ្ឌភាព និង អំពើពុករលួយដែលកើតមានយ៉ាងយូររហូតមកដែលបន្តជាឧបសគ្គដល់កិច្ចខិតខំប្រឹងប្រែងកំណែទម្រង់ ។ ក្រៅពីធ្វើការជាមួយស្ថាប័ននានារបស់រដ្ឋាភិបាល ការិយា-ល័យបានបន្តធ្វើការថែមទៀត ជាមួយអង្គការក្រៅរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិលដទៃទៀត ដើម្បីលើកស្ទួយគោលនយោបាយ និងការអនុវត្តស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិនៃប្រទេសកម្ពុជា ហើយដើម្បីជួយដល់ស្ថាប័ន និងអង្គការទាំងនោះក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីដោះស្រាយដោយមានសំណងជួសជុល និងការស្តារសម្បទាដល់ជនរងគ្រោះដោយអំពើរំលោភផ្សេងៗ និង លើបញ្ហាធំៗទាក់ទងនឹងគោលនយោបាយ និង ច្បាប់ដែលមានការប៉ះពាល់ចំពោះសិទ្ធិមនុស្ស ។

## ខ. បេសកកម្មនៃក្រុមសិក្សាស្រាវជ្រាវវាយតំលៃ

១១. ការសិក្សាស្រាវជ្រាវវាយតំលៃចំពោះការិយាល័យពីខាងក្រៅបានធ្វើឡើងកាលពីខែ តុលា និង ដើមខែ វិច្ឆិកា ឆ្នាំ ២០០៣[១] ។ គោលបំណងដ៏សំខាន់របស់ក្រុមវាយតំលៃនេះ គឺពិនិត្យមើលសកម្មភាពការងាររបស់ការិយាល័យ ដើម្បីធ្វើការប៉ាន់ប្រមាណពីផលប៉ះពាល់ សារៈសំខាន់ និងប្រសិទ្ធិភាព និង ដើម្បីកំណត់ពីបញ្ហាសំខាន់ៗទាក់ទងនឹងសិទ្ធិមនុស្ស ហើយនិងលើកឡើងនូវអនុសាសន៍មួយស្តីពីតួនាទី និង វច្ចនាសម្ព័ន្ធរបស់ការិយាល័យសំរាប់ថ្ងៃអានាគត ។ ក្រុមបេសកកម្មបានជួបជាមួយមន្ត្រីសំខាន់ៗជាច្រើនរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងតំណាងមកពីអង្គការអន្តរជាតិ និងសហគមន៍អ្នកការទូត ។ ក្នុងការធ្វើទស្សនកិច្ចនៅមូលដ្ឋាន ក្រុមបេសកកម្មបានចុះទៅទស្សនាការិយាល័យប្រចាំតំបន់ក្នុងខេត្តបាត់ដំបង បានទៅទស្សនាសហគមន៍នេសាទមួយកន្លែងដែលទទួលរងការប៉ះពាល់ដោយផលប្រយោជន៍ខាងពាណិជ្ជកម្មពីមជ្ឈដ្ឋានខាងក្រៅ និងចំការកៅស៊ូ ការិយាល័យប្រចាំកម្ពុជាកំពុងធ្វើការ

---

[១] ក្រុមវាយតំលៃមានសមាសភាព លោក វីធិត មុនថាបន (សាស្ត្រចារ្យច្បាប់ ជាប្រធានក្រុម, ព្រះរាជាណាចក្រថៃឡង់ដ៍ ) ភីធី ហែលមី (ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស / ទីក្រុងហ្សឺណែវ) និង លោក រ៉េមិន ហ្វែល (ទីប្រឹក្សា, ចក្រភពអង់គ្លេស) ។

សិក្សាស្រាវជ្រាវ ដែលជាផ្នែកមួយនៃគំរោងសិក្សាស្រាវជ្រាវរបស់ការិយាល័យ ស្តីពីចំការដាំដុះកសិកម្មដែលមានទ្រង់ទ្រាយធំ ។ ក្រុមបេសកកម្មក៏បានទៅទស្សនាពន្ធនាគារខេត្តសៀមរាប ។ របាយការណ៍របស់ក្រុមបេសកកម្មសិក្សាស្រាវជ្រាវវាយតំលៃ និងអនុសាសន៍របស់ក្រុមនេះសំរាប់ផ្ទៃក្នុងរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ហើយរបាយការណ៍នេះនឹងត្រូវពិនិត្យឡើងវិញនៅដើមឆ្នាំ២០០៤ ដើម្បីនឹងអនុវត្ត ។ ក្រុមបេសកកម្មបានលើកឡើងនូវអនុសាសន៍មួយចំនួន ដើម្បីរៀបចំរចនា-សម្ព័ន្ធឡើងវិញ និង បង្កើនប្រសិទ្ធិភាពរបស់ការិយាល័យទាក់ទងនឹងការចាត់ចែង ការគ្រប់គ្រងបុគ្គលិក និង បញ្ហាផ្សេងៗទាក់ទងនឹងថវិកា ។ អនុសាសន៍របស់សវនកម្មខាងក្រៅរបស់ អ.ស.ប ចំពោះការិយា-ល័យដែលបានធ្វើឡើងកាលពីដើមខែ ធ្នូ ឆ្នាំ ២០០៣ នឹងចាត់ទុកជាផ្នែកមួយនៃកិច្ចដំណើរការនេះ នៅពេលទទួលបានអនុសាសន៍នេះ ។

១២. ក្រុមបេសកកម្មនេះ បានរាយការណ៍ថារាល់មន្ត្រីទាំងឡាយ ដែលបានធ្វើសម្ភាសន៍បានទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ហើយបានគាំទ្រអោយការិយាល័យនេះ បន្តវត្តមានរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាតទៅទៀត យ៉ាងហោចណាស់អោយបានរហូតដល់បរិបទសិទ្ធិមនុស្សបានល្អប្រសើរដល់កំរិតមួយជាទីពេញចិត្ត ។ ក្រុមបេសកកម្មនេះបានធ្វើការសន្និដ្ឋានថា វត្តមាននៃការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាតំណាងអោយការប្តេជ្ញាចិត្តជាវិជ្ជមានមួយរបស់សហគមន៍អន្តរជាតិ ចំពោះប្រទេសកម្ពុជា បន្ទាប់ពីមានភាពវឹកវរអស់ជាច្រើនទសវត្សមក ហើយថាការិយាល័យដើរតួនាទីជា " សន្ទះបិទបើកសំរាប់ការពារសុវត្ថិភាព " ឬ " ជាអ្នកតាមឃ្លាំមើល " ការរំលោភសិទ្ធិមនុស្ស និង ជាអ្នកពិនិត្យថ្លឹងថ្លែងតុល្យភាពកុំអោយមានការរំលោភអំណាច រង់ចាំការបង្កើតអោយមានស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិមួយ ដែលឯករាជ្យ និងមានប្រសិទ្ធិភាព ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស ។ ក្រុមបេសកកម្មបានរកឃើញថាការិយាល័យ និងកម្មវិធីរបស់ខ្លួនផ្តល់អោយមានបរិយាកាសងាយស្រួលដល់ការរីកលូតលាស់នៃសង្គមស៊ីវិល ជាពិសេសគឺអង្គការក្រៅរដ្ឋាភិបាលនានាដែលធ្វើការក្នុងវិស័យសិទ្ធិមនុស្ស ។ ការិយាល័យត្រូវបានគេរកឃើញថាជា " អ្នកផ្តល់តម្លៃបន្ថែម " ក្នុងវិស័យការពារសិទ្ធិមនុស្ស និងដើរតួនាទីជាចលករ ដើម្បីបីបាច់ថែរក្សា និងគាំទ្រដល់ការងារសិទ្ធិមនុស្សរបស់តួអង្គដ៏ទៃទៀត រួមទាំងស្ថាប័នសាធារណៈ និងសង្គមស៊ីវិល ក៏ដូចជាដើរតួនាទីជាអន្តរការី ដើម្បីសំរួលការទាក់ទងដល់តួអង្គសំខាន់ៗ - ទាំងរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល - ក្នុងការផ្តល់ប្រភពមូលនិធិពីខាងក្រៅ និងពីខាងក្នុង ។

១៣. ក្រុមបេសកកម្មបានលើកឡើងជាអនុសាសន៍ដូចតទៅនេះ :

ក- សំខាន់ចាំបាច់បំផុតគឺត្រូវជួយគាំទ្រ និង ជ្រោមជ្រែងដល់តួនាទីភារកិច្ចរបស់លោកតំណាងពិសេស និងការបន្តវត្តមានរបស់ការិយាល័យប្រចាំកម្ពុជា នៅក្នុងខណៈពេលដែលសភាពការណ៍សិទ្ធិមនុស្សនៅតែជាបញ្ហាដែលគួរអោយព្រួយបារម្ភនោះ ដោយចងចាំក្នុងចិត្តអំពីអតីតកាលកន្លងទៅថ្មីៗរបស់ប្រទេសកម្ពុជា និង ការទទួលខុសត្រូវជាអន្តរជាតិចំពោះប្រជាជនកម្ពុជា ។

ខ- តួនាទីការពាររបស់ការិយាល័យ បន្ថែមតម្លៃថែមទៀតដល់បរិបទសិទ្ធិមនុស្សដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា ហើយគួរតែបង្កើនជាអតិបរិមា តាមរយៈការបង្កើនសមត្ថភាពដល់បុគ្គលការជ្រើសរើសយកករណីរឿងដែលសំខាន់ៗដែលឆ្លុះបញ្ចាំងពីនិន្នាការទូទៅជាគន្លឹះ ពិនិត្យតាមដានអោយបានពេញលេញ ជំនួយខាងគោលនយោបាយ និង បច្ចេកទេស និង លក្ខណៈវិនិច្ឆ័យច្បាស់លាស់សំរាប់ចាត់វិធានការ ។ ការិយាល័យគួរផ្តល់កិច្ចការពារចំពោះជនទាំងឡាយដែលត្រូវការការការពារជាពិសេសគឺនៅពេលដែលអង្គការដទៃទៀតមិនអាច ឬ មិនមានបំណងផ្តល់កិច្ចការពារ ។

គ- ការិយាល័យគួរតែបន្តផ្តល់ជំនួយផ្នែកច្បាប់ និង ជំនួយបច្ចេកទេសផ្សេងទៀត ក្នុងគោលបំណងលើកស្ទួយដល់ការកែប្រែរចនាសម្ព័ន្ធ និង កិច្ចសហប្រតិបត្តិការដើម្បីផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជា ។ ការិយាល័យគួរគូសបញ្ជាក់ពីការអនុវត្តច្បាប់ និងគោលនយោបាយដ៏មានប្រសិទ្ធិភាពឆ្លើយតបនិងសិទ្ធិមនុស្ស និងជួយកសាងសមត្ថភាពនៃយន្តការ និងបុគ្គលិក ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្សនៅថ្នាក់ជាតិ និងនៅថ្នាក់មូលដ្ឋាន ។

ឃ- ការិយាល័យគួរផ្តល់ជំនាញ ស្តីពីទំនាក់ទំនងរវាងប្រព័ន្ធជាតិ និងប្រព័ន្ធអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងជួយផ្តល់ពត៌មានដល់សហគមន៍ជាតិអំពីអនុសាសន៍របស់ស្ថាប័នត្រួតពិនិត្យការអនុវត្តសន្ធិ-សញ្ញាសិទ្ធិមនុស្ស និងនីតិវិធីពិសេស ដែលបានបង្កើតឡើងដោយគណៈកម្មាធិការសិទ្ធិមនុស្ស ដែលបានសរសេរជាទម្រង់ដែលងាយយល់ និងអាចប្រើប្រាស់បាន ។ ការិយាល័យគួរតាមដានឃ្លាំមើលអំពីយុទ្ធ-សាស្ត្រ និងកម្មវិធីសកម្មភាពរបស់រដ្ឋាភិបាលកម្ពុជា ស្តីពីកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានអនុម័តកាលពីខែ មិថុនា ឆ្នាំ ២០០៣ ដើម្បីធ្វើការប៉ាន់ប្រមាណពីការអនុវត្ត ស្របតាមកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា ។

ង- ការិយាល័យគួរបន្តគាំទ្រដល់សង្គមស៊ីវិល រួមទាំងអង្គការក្រៅរដ្ឋាភិបាលនានា ដែលជាកម្លាំងសំរាប់ឃ្លាំមើលសិទ្ធិមនុស្ស និង ជាស្ពានរវាងសិទ្ធិមនុស្ស និង អង្គការក្រៅរដ្ឋាភិបាលនានាខាងអភិវឌ្ឍន៍ ក្នុងខណៈដែលកំពុងពង្រីកទំនាក់ទំនងចាប់ពីអង្គការក្រៅរដ្ឋាភិបាលរហូតដល់សហគមន៍មូលដ្ឋាន និងថ្នាក់ដឹកនាំរបស់ពួកគេ។

ច- ការិយាល័យគួរគាំទ្រដល់អង្គការអន្តររដ្ឋាភិបាល និងអង្គការដទៃទៀតក្នុងការធ្វើកម្មវិធីដោយផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន។ ការិយាល័យគួរលើកយកវិស័យថ្មីៗ ដែលគួរអោយព្រួយបារម្ភដូចជាផលប៉ះពាល់ជាអវិជ្ជមាននៃការធ្វើសាកលភាវូបនីយកម្ម ដោយសហការគ្នាជាមួយទីភ្នាក់ងារដទៃទៀតរបស់ អ.ស.ប។

ឆ- តួនាទីរបស់ការិយាល័យគួរបានប្របាច់បញ្ចូលគ្នាជាកំលាំងចលករមួយវិញ ជាជាងការដើរតួនាទីជាអ្នកផ្តល់ជំនួយដែលមានសមត្ថភាព ក្នុងការបញ្ជូនបន្ត និងតភ្ជាប់ទំនាក់ទំនងទៅជាមួយនិងទីភ្នាក់ងារផ្សេងទៀតរបស់ អ.ស.ប តាមការចាំបាច់។ ការិយាល័យគួរលើកស្ទួយការគាំទ្រដែលមានតុល្យភាព និងចិរភាព ដល់មន្ត្រីមូលដ្ឋាន និងអប់រំណែនាំអោយពឹងផ្អែកលើខ្លួនឯង។

ជ- ការិយាល័យគួរសង្កត់ធ្ងន់ និង ជំរុញលើកទឹកចិត្តដល់អាជ្ញាធររដ្ឋាភិបាល និង ដៃគូរដទៃទៀតអោយអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធិភាព ដោយរដ្ឋជាសមាជិកត្រូវផ្តល់បែងចែកធនធានអោយបានទាន់ពេលវេលា និងដោយត្រឹមត្រូវស្មើភាពគ្នា។ ការិយាល័យគួរចង្អុលបង្ហាញពីការអនុវត្តដែលល្អៗ និងប្រើប្រាស់ការអនុវត្តទាំងនោះ សំរាប់ធ្វើកំណែទម្រង់ផ្នែករចនាសម្ព័ន្ធ និងលើកស្ទួយសមត្ថភាព ដើម្បីជំនះបានលើការអនុវត្តន៍ទាំងឡាយណាដែលមានលក្ខណៈជាអវិជ្ជមាន ហើយ

ញ- អនុស្សារណៈនៃកិច្ចព្រមព្រៀងបច្ចុប្បន្ន រវាងការិយាល័យ និងរដ្ឋាភិបាលកម្ពុជា គួរតែបន្តក្នុងទម្រង់នេះដដែល។

១៤. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាយល់ស្របថា សារសំខាន់ជាងគេបង្អស់ គឺត្រូវជួយគាំទ្រ និងជ្រោមជ្រែងដល់តួនាទីភារកិច្ចរបស់តំណាងពិសេសរបស់លោកអគ្គលេខាធិការ ហើយថាការបន្តមានវត្តមានរបស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុក

សិទ្ធិមនុស្សប្រចាំកម្ពុជា គឺជាការចាំបាច់បំផុត ។ ការិយាល័យសូមស្វាគមន៍ចំពោះការធានាអះអាង ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចំពោះទាំងលោកតំណាងពិសេស និងទាំងនាយិកានៃការិយាល័យ ប្រចាំកម្ពុជា នៅក្នុងកំឡុង បេសកកម្មលើកទី១០ របស់លោកតំណាងពិសេសដែលថា អោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបន្តវត្តមានតទៅទៀត ។

## គ. ការការពារសិទ្ធិមនុស្ស : ការឃ្លាំមើល ការស៊ើបអង្កេត និង ការធ្វើរបាយការណ៍

១៥. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្សនៅទូទាំងប្រទេស និងស៊ើបអង្កេតរបាយរាយការណ៍ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងបានចងក្រងជាឯកសារស្តីពីប្រភេទការរំលោភទាំងនោះ ។ ការិយាល័យបានលើកយកការព្រួយបារម្ភរបស់ខ្លួនជាប្រចាំជំរាបជូនអាជ្ញាធររដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងបានលើកស្នើនូវវិធានគោលនយោបាយដើម្បីជួសជុលការខូចខាត និងស្តារនីតិសម្បទាដល់ជនរងគ្រោះ ។ ការិយាល័យនៅតែបន្តទំនាក់ទំនងជាប្រចាំជាមួយស្ថាប័នតុលាការ អង្គការក្រៅរដ្ឋាភិបាលនានា និងសហគមន៍អន្តរជាតិលើបញ្ហាទាំងនេះ ។

១៦. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ ការិយាល័យប្រចាំកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ជាពិសេស ចំពោះការស៊ើបអង្កេតការរំលោភសិទ្ធិមនុស្ស ក្នុងបរិបទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាខែកក្កដា ឆ្នាំ ២០០៣ ។ ជាពិសេស ការិយាល័យបានស៊ើបអង្កេតករណីឃាតកម្មជាច្រើនទៅលើមន្ត្រីដែលមានការជាប់ទាក់ទងជាមួយគណបក្សនយោបាយ ។ ការិយាល័យក៏បានតាមឃ្លាំមើលការរិតត្បិតចំពោះសេរីភាពក្នុងការរួមប្រជុំ និងក្នុងការបង្កើតសមាគម នៅក្នុងរយៈពេលក្រោយពេលបោះឆ្នោត និងលើរបាយការណ៍ដទៃទៀតស្តីពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។

១៧. ការិយាល័យប្រចាំកម្ពុជាបានបន្តទទួលពាក្យបណ្តឹងពីសាធារណៈជនស្តីពីការរំលោភសិទ្ធិមនុស្ស និងបានទទួលស៊ើបអង្កេតករណីរឿងធ្ងន់ធ្ងរមួយចំនួន រួមមានករណីអំពើហឹង្សា និងការបំភិតបំភ័យលើសកម្មជនគណបក្សនយោបាយ បញ្ហាជម្លោះដីធ្លី និងការរឹបអូសយកដីធ្លី ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មឃោឃៅអមនុស្សធម៌ ឬដែលនាំអោយបាត់បង់តំលៃជាមនុស្ស នៅក្នុងកន្លែងឃុំឃាំង និងការរំលោភយ៉ាងធ្ងន់ធ្ងរ លើការធានាការពារដល់កិច្ចដំណើររឿងព្រហ្មទណ្ឌ ។ បុគ្គលិករបស់ការិយាល័យក៏បានពិនិត្យតាមដានអំពីការរីកចំរើននៃករណីទាក់ទងនិងជនជាប់ចោទ ពីបទកុប្បកម្មប្រឆាំងនឹងថៃ កាលពីថ្ងៃទី ២៩ ខែ

មករា ឆ្នាំ ២០០៣ ដែលតុលាការបានបើកសវនាការជំនុំជំរះកាលពីខែ កញ្ញា ឆ្នាំ ២០០៣។ មានជនជាប់ចោទចំនួន៤៧ នាក់ ត្រូវគេរកឃើញថាមានទោសពីបទធ្វើកុប្បកម្មដោយផ្ទាល់ ហើយត្រូវបានតុលាការកាត់អោយជាប់ពន្ធនាគារស្មើនឹងរយៈពេលដែលខ្លួនបានជាប់ឃុំរួចហើយនោះ ត្រូវបានដោះលែងហើយ ។ និស្សិតចំនួន២ នាក់ត្រូវជាប់ចោទពីបទញុះញង់អោយមានបទល្មើស ហើយត្រូវតុលាការកាត់អោយជាប់ពន្ធនាគាររយៈពេលវែងជាង ត្រូវបានដោះលែងក្នុងរយៈពេល៣ សប្តាហ៏បន្ទាប់ពីនោះ ក្រោយពេលដែលព្រះមហាក្សត្របានព្រះរាជប្រទានការលើកលែងទោស ។ ការចោទប្រកាន់នៅតែបន្តធ្វើចំពោះអ្នកកាសែត២ រូប ពីបទញុះញង់អោយប្រព្រឹត្តបទល្មើស ត្រូវបានធានាអោយនៅក្រៅឃុំរង់ចាំសវនាការ ។ ការិយាល័យបាន តាមដានការងារកន្លងមក ទាក់ទងនឹងការចងគំនុំតាមដងផ្លូវ (ការសំលាប់ដោយហ្វូងមនុស្ស) និងស្ថានភាពពន្ធនាគារ  បានបន្តធ្វើការស៊ើបអង្កេតករណីរឿងនានាដែលមិនទាន់ដោះស្រាយរួច និងជួយអង្គការក្រៅរដ្ឋាភិបាលនានាខាងសិទ្ធិមនុស្ស ក្នុងការអនុវត្តការងាររបស់ខ្លួនអោយមានប្រសិទ្ធិភាព ។ ការិយាល័យក៏បានជួយការពារសុវត្ថិភាពដល់អ្នកការពារក្តីខាងសិទ្ធិមនុស្សក្នុងស្រុកដែលកំពុង ប្រឈមមុខនឹងការគំរាមកំហែង ។

## ឃ- កម្មវិធីបោះឆ្នោត

១៨.    ក្នុងអំឡុងពេលធ្វើរបាយការណ៏ទាំងមូល ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តកម្មវិធីរបស់ខ្លួនទាក់ទងនិងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលបានរៀបចំធ្វើឡើង កាលពីខែកក្កដា ឆ្នាំ ២០០៣ ដើម្បីលើកស្ទួយដល់បរិយាកាសនយោបាយដែលគ្មានអំពើហឹង្សា និងការបំភិតបំភ័យ និងកិច្ចដំណើរការបោះឆ្នោតដែលគ្រប់គ្រងដោយស្ថាប័នរដ្ឋដែលអព្យាក្រិត ។ ក្រុមចល័តចំនួន៣ក្រុម បានបន្តធ្វើការស៊ើបអង្កេតលើរបាយការណ៏បោះឆ្នោតទាក់ទងនឹងការរំលោភសិទ្ធិមនុស្សនៅទូទាំងប្រទេស និងបានតាមឃ្លាំមើលសភាពការណ៏នយោបាយទូទៅ ។ ការិយាល័យបោះឆ្នោតប្រចាំខេត្តកំពង់ចាម បានបន្តតាមឃ្លាំមើលយ៉ាងជិតដល់លើសភាពការណ៏នៅក្នុងខេត្ត ធ្វើការស៊ើបអង្កេតករណីរឿងធ្ងន់ធ្ងរ និងស្នើសុំអន្តរាគមន៏ពីអាជ្ញាធរថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ។ កម្មវិធីបោះឆ្នោតត្រូវចប់សព្វគ្រប់នៅចុងខែមករា ឆ្នាំ ២០០៤ ។

១៩. បុគ្គលិកការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានជួបជារឿយៗជាមួយតំណាង និងមន្ត្រីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីលើកពីបញ្ហាគួរអោយព្រួយបារម្ភទូទៅ និងបញ្ហាករណីរឿងជាក់លាក់ដែលទាក់ទងមួយចំនួន ជាពិសេសស្តីពីការចាត់ការក្នុងការដោះ

ស្រាយចំពោះពាក្យបណ្តឹងពីការបំភិតបំភ័យ និងអំពើហឹង្សាក្នុងបរិបទនៃការបោះឆ្នោត និងការអនុវត្ត ទណ្ឌកម្ម ។ នៅក្នុងអំឡុងពេលក្រោយការបោះឆ្នោត ការិយាល័យបានលើកឡើងជាច្រើនដងជាបន្តបន្ទាប់ អំពីការព្រួយបារម្ភរបស់ខ្លួន ជំរាបប្រាប់ក្រសួងមហាផ្ទៃ នគរបាល និង អាជ្ញាធរក្រុងស្តីពីការរឹតបន្តឹង ចំពោះសេរីភាពក្នុងការរួមប្រជុំ  និង ការប្រើប្រាស់កំលាំងហួសហេតុ ដើម្បីបំបែកហ្វូងបាតុករដែលគ្មាន ការអនុញ្ញាត្ត ។

២០. ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តតាមឃ្លាំមើលការ ខិតខំប្រឹងប្រែងក្នុងការអនុវត្តច្បាប់ និងចំណាត់ការរបស់តុលាការទាក់ទងនិងករណីឃាតកម្ម និងករណី ការស្លាប់ដែលគួរអោយសង្ស័យថាជារឿងនយោបាយ បន្ថែមទៅលើករណីនៃអំពើហឹង្សា និងការបំភិត បំភ័យតាមរូបភាពដទៃទៀតចំពោះសកម្មជនគណបក្សនយោបាយ ។ ការិយាល័យបានបន្តបង្កើតបញ្ជី ទិន្នន័យដើម្បីកត់ត្រាអំពីការរំលោភសិទ្ធិមនុស្សដែលបានរាយការណ៍ថាទាក់ទងនិងការបោះឆ្នោត ។ មន្ត្រី របស់ការិយាល័យបានរៀបចំការប្រជុំជាមួយតំណាងគណៈបក្សនយោបាយធំៗទាំងអស់ និង បានរាយ-ការណ៍ត្រួសៗ ជូនសហគមន៍អ្នកការទូត ប្រទេសអ្នកផ្តល់ជំនួយ និង អង្គការអន្តរជាតិ ។ ការិយាល័យបាន បន្តខិតខំសម្របសំរួលការងារជាមួយមន្ត្រីបោះឆ្នោតថ្នាក់មូលដ្ឋាន និង ជាមួយអង្គការក្រៅរដ្ឋាភិបាល នានាខាងសិទ្ធិមនុស្ស បានទទួលរៀបចំប្រជុំជាប្រចាំ ដើម្បីពិភាក្សាបញ្ហាដែលមានការព្រួយបារម្ភជារួម ។ កិច្ចសហប្រតិបត្តិការនេះ បានពង្រីករហូតដល់ខេត្តនានា ដោយមានមន្ត្រីរបស់ការិយាល័យជួយគាំទ្រដល់ អង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការតាមឃ្លាំមើល និងការស៊ើបអង្កេត ។

## ង- ការសិក្សាស្រាវជ្រាវអំពីបញ្ហានិទណ្ឌភាព

២១.  ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានចាប់ផ្តើមគំរោង កម្មវិធីមួយ នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៣ ដើម្បីពិនិត្យសើរើឡើងវិញ និងតាមដានពីករណីរឿងរំលោភ សិទ្ធិមនុស្សផ្សេងៗ ដែលអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) បានបញ្ជូន ទៅអោយចាត់វិធានការកាលពីឆ្នាំ១៩៩២ និង ១៩៩៣ ក៏ដូចជាការិយាល័យ និង លោកតំណាងពិសេស បានបញ្ជូនទៅនៅក្នុងអម្លុងទស្សវត្សបន្តមកទៀត ។ ផ្អែកលើមូលដ្ឋាននៃការពិនិត្យសើរើឡើងវិញនេះ និងការវិភាគអំពីការរីកចំរើនខាងផ្នែកច្បាប់ និងខាងនយោបាយដែលទាក់ទង ការិយាល័យនឹងរៀងចំធ្វើ ជារបាយការណ៍មួយដែលក្នុងនោះមានលើកឡើងនូវអនុសាសន៍ផងដែរ ។  ការិយាល័យក៏នឹងរៀបចំ

បង្កើតជាយុទ្ធសាស្ត្រសំរាប់រយៈ ពេលមួយវែងមួយស្តីពីថាតើត្រូវធ្វើយ៉ាងណាដើម្បីដោះស្រាយចំពោះបញ្ហានិទណ្ឌភាពអោយបានប្រកបដោយប្រសិទ្ធិភាព ។

## ច- គំរោងកម្មវិធីផ្នែកដីធ្លី

២២. ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តការសិក្សាស្រាវជ្រាវរបស់ខ្លួនអំពីការដាំដុះដំណាំកសិកម្មដែលមានទ្រង់ទ្រាយធំ-ការសិក្សាស្រាវជ្រាវមួយ ដែលក្នុងនោះអំពីសម្បទានដី និង ចំការកៅស៊ូដែលគ្រប់គ្រងដោយរដ្ឋ - ដើម្បីរកអោយឃើញពីផលប៉ះពាល់ដល់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងបរិវេណ និងជិតព្រំប្រទល់ដីសម្បទាន ឬចំការកៅស៊ូទាំងនោះ ។ ការិយាល័យបានបន្តការស្រាវជ្រាវ ធ្វើរបាយការណ៍ វិភាគ និងតាមឃ្លាំមើលសភាពការណ៍សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។ ការិយាល័យបានចុះទៅធ្វើការផ្ទាល់ដល់មូលដ្ឋាន ក្នុងតំបន់ដែលបានជ្រើសរើសមួយចំនួន នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ និងបានស៊ើបអង្កេត និងចងក្រងជាឯកសារស្តីពីសភាពការណ៍សិទ្ធិមនុស្សនៅក្នុងដីសម្បទានចំនួន ៤ កន្លែង នៅក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ (ដែលគ្រប់គ្រងដោយក្រុមហ៊ុនមួយចំនួនដូចជា : ក្រុមហ៊ុនហៃហានទិញ ខាំបូឌៀ ក្រុមហ៊ុនស៊ីចេខាំបូឌៀ និងក្រុមហ៊ុនអាដូក ) ដីសម្បទានមួយកន្លែងឈ្មោះ ភាពពីម៉ិច នៅក្នុង ខេត្តកំពង់ឆ្នាំង និងនៅចំការកៅស៊ូទឹរីង ។

២៣. បច្ចុប្បន្ននេះ ការងារស្រាវជ្រាវដល់មូលដ្ឋាន បានធ្វើឡើងនៅក្នុងដីសម្បទានចំនួន៩ កន្លែង និងចំការកៅស៊ូមួយកន្លែង ។ ការស្រាវជ្រាវជាលំអិតបានធ្វើឡើងនៅក្នុងដីសម្បទានចំនួន៣កន្លែងក្នុងចំណោមដីសម្បទានទាំងនេះ ដោយរួមទាំងការសម្ភាសន៍ពីគុណភាពពាក់កណ្តាលរចនាសម្ព័ន្ធជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន សកម្មជន អាជ្ញាធរនានា និង តំណាងក្រុមហ៊ុនសម្បទាន ។ មន្ត្រីរបស់ការិយាល័យក៏បានធ្វើការសម្ភាសន៍ជាចំហរជាមួយអង្គការក្រៅរដ្ឋាភិបាលនៅថ្នាក់ខេត្ត និង ថ្នាក់ជាតិ ហើយបានជួបប្រជុំជាប្រចាំនៅក្នុងអំឡុងពេលនៃការសិក្សាស្រាវជាមួយមន្ត្រីទាំងឡាយដែលមានភារកិច្ចទាក់ទងនិងការងារគ្រប់គ្រង និងគោលនយោបាយដីធ្លី នៅក្នុងប្រទេសកម្ពុជា រួមទាំងមន្ត្រីពាក់ព័ន្ធរបស់រដ្ឋាភិបាល ទាំងថ្នាក់ជាតិ ទាំងថ្នាក់ខេត្ត សង្គមស៊ីវិល និងទីភ្នាក់ងារអន្តរជាតិនានា ។

២៤. ការសិក្សាស្រាវជ្រាវក៏បានស្វែងរកអោយឃើញផងដែរអំពីថាតើដីសម្បទាន បានរួមចំណែកអ្វីខ្លះដល់ការអភិវឌ្ឍន៍ និងសុខមាលភាព និងដល់វិស័យសេដ្ឋកិច្ច និង សង្គមកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូល ។ បើនិយាយអោយចំ តើការរួមវិភាគទានអ្វីខ្លះដល់ចំណូលជាតិទាំងមូល និង ដល់ជីវភាពរស់នៅ

របស់ប្រជាពលរដ្ឋមូលដ្ឋានដែលទទួលរងនូវផលប៉ះពាល់ពីសម្បទានទាំងនេះ? ។ ការិយាល័យបានប្រមូលទិន្នន័យស្តីពីសម្បទានដែលមានស្រាប់ និងបានធ្វើការប៉ាន់ប្រមាណពីការដែលសម្បទានិកគោរពតាមច្បាប់ភូមិបាលឆ្នាំ២០០១ និង លក្ខខណ្ឌនៃកិច្ចសន្យាសម្បទាន ។ ការិយាល័យក៏បានខិតខំរកវិធីធ្វើយ៉ាងណាដើម្បីអោយបានចូលរួមផ្តល់យោបល់នៅក្នុងដំណើរការព្រៀងអនុក្រឹត្យផ្សេងៗ ដែលសំខាន់សំរាប់អនុវត្តច្បាប់ភូមិបាល ជាពិសេសបំផុតនោះគឺអនុក្រឹត្យស្តីពីនីតិវិធីផ្តល់សម្បទានដី ដើម្បីគោលបំណងសេដ្ឋកិច្ច និងអនុក្រឹត្យស្តីពីការកាត់បន្ថយ និងការលើកលែងចំពោះករណីជាក់ស្តែងមួយចំនួន នៃសម្បទានដីដែលមានទំហំលើសពី ១០.០០០ ហិតា ។

២៥. បើតាមពតិមានដែលក្រសួងកសិកម្មបានផ្តល់អោយកាលពីខែកម្ភះ ឆ្នាំ ២០០៣ គណៈរដ្ឋមន្ត្រីបានអនុម័តសម្បទានដីចំនួន ៤២ កន្លែងសំរាប់គោលបំណងកសិកម្ម ដែលមានផ្ទៃដីទាំងអស់ ៨០០.០០០ ហិតា ។ ក្នុងនោះមានតែ២៧ ករណីប៉ុណ្ណោះ ដែលបានអនុវត្តកិច្ចព្រមព្រៀង ឬកិច្ចសន្យាសម្បទានជាមួយក្រសួង ។ ចាប់ពីពេលដែលការិយាល័យចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវ មានតែសម្បទានដែលបានអនុម័តរួចចំនួន ៥ ប៉ុណ្ណោះត្រូវបានលុបចោលវិញកាលពីខែ សីហា ឆ្នាំ ២០០៣ ហើយនៅមានសម្បទានចំនួន១១ ទៀត ដែលរដ្ឋមន្ត្រីក្រសួងកសិកម្មបានប្រមាន នឹងលប់ចោល ។ ក៏ប៉ុន្តែមិនទាន់ឃើញមានបញ្ជប់កិច្ចសន្យាណាមួយដែលមានស្រាប់នៅឡើយទេ ។ ទោះបីជាមានក្រុមហ៊ុនខ្លះបានរំលោភយ៉ាងច្បាស់ក្រឡែតលើកិច្ចសន្យារបស់ខ្លួន និងច្បាប់កម្ពុជាក៏ដោយ ។ លោកតំណាងពិសេសបានលើកឡើងជាអនុសាសន៍លប់ចោលនូវកិច្ចសន្យាទាំងឡាយណាដែលសម្បទានិករំលោភច្បាប់ ឬ រំលោភយ៉ាងធ្ងន់ធ្ងរលើលក្ខខណ្ឌនៃកិច្ចសន្យា ។

២៦. ក្នុងការធ្វើការសិក្សាស្រាវជ្រាវនេះ មន្ត្រីរបស់ការិយាល័យបានជួបប្រទះការលំបាកជាច្រើន ក្នុងការស្វែងរកពតិមានស្តីពីសម្បទានដី ទោះបីពតិមាននេះទាក់ទងនិងផលប្រយោជន៍ដ៏សំខាន់របស់សាធារណៈជនដែលត្រូវតែផ្សព្វផ្សាយជាសាធារណៈក៏ដោយ (ដូចជានីតិវិធីស្តីពីការផ្តល់ដីសម្បទានថ្មី ថ្លៃឈ្នួលកិច្ចសន្យា ម្ចាស់ភាគហ៊ុន ការបង់ប្រាក់កក់ ថ្លៃឈ្នួល និង ផែនទីជាដើម) ។ សូម្បីតែនៅពេលដែលការិយាល័យអាចសុំមើលកិច្ចសន្យាបានក៏ដោយ ក៏ការិយាល័យ មិនអាចស្គាល់អត្តសញ្ញាណរបស់អ្នកម្ចាស់ភាគហ៊ុនម្នាក់ៗនៃក្រុមហ៊ុនពាក់ព័ន្ធនោះបានដែរ ។ ការលំបាកក្នុងការស្វែងរកពតិមានដូចនេះ ជាការបង្ហាញអោយឃើញពីភាពត្រូវការចាំបាច់ជាបន្ទាន់មួយ អោយមានគោលនយោបាយ និង ការអនុវត្តផ្នែករដ្ឋបាលដែលលក្ខណៈបើកចំហរជាងនេះ ដើម្បីអាចអោយធ្វើការជជែកពិភាក្សា ផ្លាស់ប្តូរពតិមានគ្នាបាន

ស្ដីពីបញ្ហាដីធ្លីនៅក្នុងប្រទេសកម្ពុជា និងដើម្បីអោយការធ្វើសេចក្ដីសំរេចក្នុងការគ្រប់គ្រងដីធ្លី និងការបង្កើតគោលនយោបាយបានកាន់តែល្អប្រសើរថែមទៀត ។ ជាការចាំបាច់ផងដែរនោះគឺត្រូវការអោយមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន និង អោយមានបរិយាកាសមួយដែលមានច្បាប់ទម្លាប់គ្រប់គ្រងត្រឹមត្រូវ ប្រកបដោយប្រសិទ្ធិភាព ដើម្បីអាចសង្កេតឃ្លាំមើលសកម្មភាពរបស់ក្រុមហ៊ុនសម្បទានទាំងនោះ និងធានាអោយគេគោរពតាមច្បាប់ និងលក្ខខណ្ឌនៃកិច្ចសន្យាអោយបានត្រឹមត្រូវ ។ លោកតំណាងពិសេសបានលើកឡើង ជាអនុសាសន៍សុំអោយអនុម័តច្បាប់ស្ដីសេរីភាពខាងពត៌មានដែលអនុញ្ញាតអោយមានការពិនិត្យតាមដានល្អិតល្អន់ចំពោះសកម្មភាពរបស់អង្គការនីតិប្រតិបត្តិ និងជំរុញលើកទឹកចិត្តអោយមានការទទួលខុសត្រូវកាន់តែខ្លាំងថែមទៀត ។ មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនបាន និងកំពុងធ្វើការងារទាក់ទងនិងបញ្ហាទាំងនេះ ។

២៧. ការិយាល័យក៏បានស៊ើបអង្កេត និងចងក្រងជាឯកសារអំពីករណីរឿងជំលោះដីធ្លី និងធនធានធម្មជាតិផ្សេងៗទៀត នៅក្នុងរយៈពេលធ្វើរបាយការណ៍នេះ ។ ជារឿយៗ បញ្ហាទាំងនោះពាក់ព័ន្ធនឹងជំលោះរវាងប្រជាពលរដ្ឋមូលដ្ឋាន ឬអ្នកនេសាទ និងអ្នកមានឥទ្ធិពលខាងសេដ្ឋកិច្ច និង នយោបាយ រួមទាំងនាយទាហាន អ្នកដែលមានផលប្រយោជន៍ខាងអាជីវកម្ម ។ ការសិក្សាលំអិតស្ដីពីករណីទាំងនេះបានជួយដល់ការរៀបចំចងក្រងជាឯកសារ និង លើកឡើងអំពីបញ្ហាដែលកើតឡើងជាថ្មីម្ដងទៀត ទាំងក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងទាំងក្នុងយន្ដការសំរាប់ដោះស្រាយជំលោះដីធ្លី និងការរំលោភលើសិទ្ធិមនុស្ស ។ បច្ចុប្បន្ននេះ ទាំងរច្ចនាសម្ព័ន្ធគណៈកម្មាធិការសុរិយោដីដែលបានបង្កើតកាលពីខែកក្កដា ឆ្នាំ ២០០២ គឺសុទ្ធតែមិនទាន់បានដំណើរការប្រកបដោយប្រសិទ្ធិភាពដើម្បីដោះស្រាយជំលោះដីធ្លី ឬផ្ដល់ការជួសជុលសំណងការខូចខាតចំពោះការរំលោភសិទ្ធិមនុស្សនៅឡើយទេ ។

## ឆ- សិទ្ធិមនុស្សក្នុងការអភិវឌ្ឍន៍ រួមទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

២៨. ការិយាល័យបានបន្ដជួយគាំទ្រអោយគោលនយោបាយជាតិ ផ្អែកលើមូលដ្ឋាននៃកាតព្វកិច្ចសិទ្ធិមនុស្សអន្ដរជាតិ ក្នុងវិស័យទាំងឡាយដូចជាការអភិវឌ្ឍន៍ទីក្រុង សុខភាព បរិស្ថាន ការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិ និងអោយដាក់បញ្ចូលនូវបទដ្ឋានសិទ្ធិមនុស្សអន្ដរជាតិទាំងស្រុងនៅក្នុងយុទ្ធសាស្ដ្រជាតិកាត់បន្ថយភាពក្រីក្រ ហើយនិងនៅក្នុងការអនុវត្តអោយបានសំរេចទិសដៅអភិវឌ្ឍន៍សំរាប់សហសវត្ស ។ ការិយាល័យបានធ្វើការជាមួយអង្គការអភិវឌ្ឍន៍នានា ដើម្បីបញ្ចូលសិទ្ធិមនុស្សជា

ពិសេសផ្តោតការយកចិត្តទុកដាក់លើកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ក្នុងគោលបំណងដើម្បីពង្រឹងអោយមានការទទួលខុសត្រូវ ។

២៩. ការិយាល័យបានបន្តកិច្ចសហប្រតិបត្តិការ និងគាំទ្រចំពោះការងាររបស់អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ទាំងឡាយដែលគាំទ្រដល់សិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច ។ ការិយាល័យបានរៀបចំកំណត់មួយស្តីពីសិទ្ធិត្រូវមានទីជំរកគ្រប់គ្រាន់ ដើម្បីអោយក្រុមមនុស្សដែលទទួលរងនូវផលប៉ះពាល់ និង តំណាងរបស់ពួកគេបានដឹង ។ ការិយាល័យបានលើកឡើងអំពីសេចក្តីព្រួយបារម្ភជំរាបដល់សាលាក្រុងភ្នំពេញចំពោះបញ្ហាអោយទៅតាំងទីលំនៅថ្មី និង បណ្តេញប្រជាពលរដ្ឋចេញដោយបង្ខំដែលរស់នៅក្នុងសំណង់អានាធិបតេយ្យ និង ប្រជាពលរដ្ឋក្រីក្រនៅទីក្រុងភ្នំពេញ និង បានធ្វើអន្តរាគមន៍ជាច្រើនលើកច្រើនសារដើម្បីព្យាយាមបញ្ឈប់ការបណ្តេញចេញដោយបង្ខំទាំងនេះ ។

៣០. ការិយាល័យក៏បានផ្តោតការយកចិត្តដាក់ចំពោះសិទ្ធិខាងសុខភាពដោយចាត់ទុកថាជាបញ្ហាស្នូលដែលបញ្ហានេះ ត្រូវបានលោកតំណាងពិសេសលើកឡើង នៅក្នុងអំឡុងពេលបេសកកម្មលើកទី១០ របស់លោក ។ ភាពក្រីក្រ និង បញ្ហាសុខភាពមានការទាក់ទងគ្នាខ្លាំងណាស់នៅក្នុងប្រទេសកម្ពុជា ។ ប្រជាពល-រដ្ឋដែលមានជីវភាពក្រីក្រ មិនអាចមានសិទ្ធិទទួលការថែទាំសុខភាពដោយស្មើភាពបានដូចគេឡើយ ហើយជារឿយៗពួកគេត្រូវជំពាក់បំណុល ដោយសារខ្ចីប្រាក់គេដើម្បីបង់ថ្លៃពេទ្យ ដែលជាការធ្វើអោយប៉ះពាល់ដល់ស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងនោះ ។ ការិយាល័យ បានបន្តផ្តល់ជំនួយជាហិរញ្ញវត្ថុ និង ជំនួយផ្សេងទៀតដល់ការងាររបស់សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយដែលលើកស្ទួយចំណេះដឹងខាងច្បាប់ ការរៀបចំជាបណ្តាញ និងធ្វើការតស៊ូមតិនៅក្នុងចំណោមសហគមន៍នេសាទទាំងឡាយ ដែលមានទីតាំងនៅជុំវិញបឹងទន្លេសាប ។

៣១. បុគ្គលិកការិយាល័យបាននិងកំពុងពិនិត្យឡើងវិញ និង ធ្វើបច្ចុប្បន្នភាពកម្មវិធីហ្វឹកហ្វឺនជាមូលដ្ឋានស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ដែលផ្តោតការយកចិត្តទុកដាក់លើសិទ្ធិខាងសុខភាពអប់រំ និងសិទ្ធិមានទីជំរក និងសិទ្ធិមានជីវភាពរស់នៅក្នុងកំរិតអប្បបរិមា ។

## ជ- ក្របខ័ណ្ឌនៃនីតិរដ្ឋ

### (ក) តុលាការ និង ការគ្រប់គ្រងប្រព័ន្ធយុត្តិធមិ

៣២. ការិយាល័យបានបន្តតាមឃ្លាំមើលកំណែទម្រង់ផ្នែកយុត្តិធមិ ដើម្បីសម្រួលដល់ការដាក់បញ្ចូលច្បាប់សិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់ក្នុងស្រុក និង ការអនុវត្តក្នុងស្រុក ហើយដើម្បីផ្សាភ្ជាប់របៀបវារៈកំណែទម្រង់អោយបានល្អថែមជាមួយនិងវិស័យដទៃទៀត នៃគោលនយោបាយរបស់រដ្ឋាភិបាលដូចជាយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និង ការវិនិយោគផ្នែកឯកជន ដែលពឹងផ្អែកលើស្ថាប័នច្បាប់ដែលមានសមត្ថកិច្ចមានការទទួលខុសត្រូវ និងមានតម្លាភាព ។ ការិយាល័យបានគាំទ្រអោយធ្វើកំណែទម្រង់រច្ចនាសម្ព័ន្ធនៃស្ថាប័នសំខាន់ៗមួយចំនួនដូចជាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ការិយាល័យបានរក្សាវត្តមានរបស់ខ្លួននៅតុលាការក្រុងភ្នំពេញ និងបានតភ្ជាប់ទំនាក់ទំនងតទៅទៀតជាមួយសាលាឧទ្ធរណ៍ និងតុលាការកំពូល ។ ការិយាល័យបានបន្តកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយតុលាការខេត្តបាត់ដំបង តាមរយៈការិយាល័យប្រចាំតំបន់ បន្ថែមដោយការធ្វើទស្សនកិច្ចជាប្រចាំដោយបុគ្គលិកនៃការិយាល័យថ្នាក់ជាតិ ។ ដើម្បីអោយការប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធិភាពថែមទៀត ក៏ដូចជាដើម្បីពង្រឹងការិយា-ល័យរបស់ខ្លួននៅតុលាការក្រុងភ្នំពេញ (ដែលទទួលពាក្យបណ្តឹងចំនួន៨០០០ ករណីក្នុងមួយឆ្នាំៗ)ការិយាល័យតូចមួយនៅតុលាការក្រុងព្រះសីហនុត្រូវបានបិទទ្វារ តែនៅមានមន្ត្រីបន្តជួយពីភ្នំពេញ ។

៣៣. ការិយាល័យបានបន្តជួយដល់តុលាការនានា ដើម្បីលើកស្ទួយការគោរពតាមបទដ្ឋានសិទ្ធិមនុស្ស និងដើម្បីដោះស្រាយចំពោះបញ្ហាការអនុវត្តជាច្រើន នៅក្នុងប្រព័ន្ធយុត្តិធមិព្រហ្មទណ្ឌ ដែលច្បាប់ហាក់ដូចជាមិនបានដាក់ទណ្ឌកម្ម ។ មន្ត្រីការិយាល័យបានតាមឃ្លាំមើលសវនាការជំនុំជំរះក្តីនៃករណីរឿងសំខាន់ៗដែលមានការព្រួយបារម្ភ ដោយរួមទាំងករណីរឿងដែល ពាក់ព័ន្ធនិងការជួញដូរមនុស្ស ការធ្វើទារុណកម្មអំពើហិង្សាផ្លូវភេទប្រឆាំងនិងកុមារ កុប្បកម្មប្រឆាំង និងថៃ កាលពីថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៣ និងសវនាការដែលធ្វើឡើងកាលពីខែតុលា លើក្នុងករណីរឿងឃាតកម្ម លោកឱម រដ្ឋសាឌី ទីប្រឹក្សាជាន់ខ្ពស់របស់គណបក្សហ៊្វុនស៊ីនប៉ិច (រណៈសិរ្សជាតិកម្ពុជា ដើម្បីឯករាជ្យ អាព្យាក្រិត្យ សន្តិភាព និងសហប្រតិបត្តិការ) ។ ក្រៅពីករណីរឿងនៅក្នុងតុលាការក្រុងភ្នំពេញ សាលា ឧទ្ធរណ៍ តុលាការកំពូល ការិយាល័យបានតាមតានករណីរឿង នៅក្នុងតុលាការខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ក្រុងព្រះសីហនុ និងខេត្តបាត់ដំបង ។ ការិយាល័យបានផ្តល់ការណែនាំស្តីពីសិទ្ធិ និងនីតិវិធីជំនុំជំរះត្រឹមត្រូវតាមផ្លូវច្បាប់ ហើយបានលើកឡើងពីបញ្ហាទាក់ទងនិងមេធាវីតំណាង និងសិទ្ធិដោះស្រាយរឿងក្តីតាមផ្លូវតុលាការ សម្រប

សម្រួលទំនាក់ទំនងរវាងជនជាប់ចោទ និង មេធាវីការពារជនក្រីក្រ នៅពេលណាដែលមានករណីរឿងធំៗ ត្រូវបើកសវនាការជំនុំជំរះនៅក្នុងតុលាការតែគ្មានមេធាវីតំណាង។ ការិយាល័យក៏បានពិនិត្យតាមដានអំពីទំនាក់ទំនងរវាងតុលាការ និង នគរបាល។

៣៤. ក្រុមបេសកកម្មរបស់ អ.ស.ប សំរាប់សិក្សាវាយតំលៃខាងបច្ចេកទេស ក្នុងការជួយឧបត្ថម្ភសំរាប់ការកាត់ទោសមេដឹកនាំខ្មែរក្រហម បានមកពេញបេសកកម្មនៅទីក្រុងភ្នំពេញកាលពីដើមខែធ្នូកន្លងមកនេះ។ ក្រុមបេសកកម្មបានឈានដល់ការព្រមព្រៀង" ជាដំកំភួន" ជាមួយក្រុមការងាររបស់រដ្ឋាភិបាលលើកបញ្ហាជាច្រើនរួមមានបញ្ហាទាក់ទងនឹងបុគ្គលិក និងលំដាប់លំដោយការងារដែលត្រូវត្រៀមរៀបចំសំរាប់តំណាក់ការបង្កើតអង្គជំនុំជំរះវិសាម័ញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យតាមច្បាប់កម្ពុជា។ ការិយាល័យបានបន្តតាមដានការវិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា ហើយបានផ្តល់សេចក្តីរាយការណ៍អំពីសភាពការណ៍សិទ្ធិមនុស្ស និងការគ្រប់គ្រងប្រព័ន្ធយុត្តិធមិ។ ការិយាល័យយល់ឃើញថាការងាររបស់ខ្លួនមានសារសំខាន់ណាស់ទាក់ទងនឹងការអប់រំដល់សាធារណជន និង អាចដើរតួនាទីផងដែរក្នុងការ សង្កេតមើលសវនាការជំនុំជំរះក្តី។

៣៥. ការិយាល័យបានជួបប្រជុំជាទៀងទាត់ជាមួយមន្ត្រីតុលាការ សមាជិកនៃអង្គនីតិបញ្ញត្តិ និង មន្ត្រីរដ្ឋាភិបាល ដើម្បីពិភាក្សាអំពីបញ្ហាច្បាប់ និង គោលនយោបាយផ្សេងៗស្តីពីសិទ្ធិមនុស្សក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធមិ រួមមានការជួបប្រជុំជាមួយអ្នកច្បាប់ ចៅក្រម និងព្រះរាជអាជ្ញា ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មន្ត្រីក្រសួងយុត្តិធមិ ប្រធានគណៈកម្មាការនានានៃរដ្ឋសភា។ ប្រធានបទនៃការពិភាក្សារួមមានស្តីពីឯករាជ្យភាពនៃតុលាការ បញ្ហាកំណែទម្រង់ស្តីពីស្ថាប័នយុត្តិធមិ និង វិជ្ជាជីវៈច្បាប់ ការព្រួយបារម្ភពីបញ្ហាសន្តិសុខរបស់ចៅក្រម និងបុគ្គលិកតុលាការករណីរឿងកកស្ទះនៅក្នុងប្រព័ន្ធតុលាការ ការកាត់ទោស និងគោលការណ៍ក្នុងការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា។ ការិយាល័យបានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធផងដែរជាមួយអង្គការក្រៅរដ្ឋាភិបាលនានា លើបញ្ហាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធតុលាការ។

៣៦. នៅពេលថ្មីៗនេះ ការិយាល័យបានចូលរួមពិគ្រោះយោបល់លើឯកសារស្តីពីយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និង តុលាការដែលបានអនុម័តដោយរដ្ឋាភិបាលកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣។ អង្គសិក្ខាសាលាជាច្រើនបានធ្វើឡើងជាបន្តបន្ទាប់ ចាប់ផ្តើមពីខែតុលា ឆ្នាំ២០០៣ មក ដើម្បីកំណត់អាទិភាពលើ

សេចក្តីព្រាងកម្មវិធីផែនការសកម្មភាពរបស់រដ្ឋាភិបាល ដែលក្នុងនោះមានសកម្មភាពចំនួនជាង ៩០ សកម្មភាព ។ ការិយាល័យបានស្វាគមន៏ចំពោះការបើកទូលាយជាងមុន ក្នុងការចូលរួមនៅក្នុងដំណាក់កាលនៃការពិភាក្សានេះ ជាពិសេសដោយសារកាលពីពេលរៀបចំព្រាងឯកសារយុទ្ធសាស្ត្រនេះ គេមិនមានធ្វើការពិគ្រោះយោបល់ទូលំទូលាយដូចនេះទេ ។ ការិយាល័យប្រចាំកម្ពុជាទទូចជាដដែល១ថា: នៅក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវតែអោយមានការចូលរួមអោយបានច្រើនថែមទៀត ដើម្បីទទួលបានការគាំទ្រអោយបានទូលំទូលាយថែមទៀតពីប្រជាពលរដ្ឋកម្ពុជា ។

៣៧. ការខកខានរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការបំពេញភារកិច្ចទទួលខុសត្រូវរបស់ខ្លួនក្នុងការពិនិត្យអោយបានល្អិត និងការថែរក្សាការពារឯករាជ្យភាព និងសីលធម៌វិជ្ជាជីវចៅក្រម និងព្រះរាជអាជ្ញាស្ថិតនៅជាឧបសគ្គមួយ ចំពោះការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាពនៃស្ថាប័នតុលាការនៅក្នុងប្រទេសកម្ពុជាជាដដែល ។ ការរៀបចំរច្ចនាសម្ព័ន្ធនៃក្រុមប្រឹក្សានេះជាថ្មីឡើងវិញ ស្ថិតនៅតែជាបញ្ហាអាទិភាពនៅក្នុងរបៀបវារៈស្តីពីកំណែទម្រង់ជាដដែល ហើយដែលនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មលើបញ្ហានេះថែងនៅមិនទាន់គ្រប់គ្រាន់ទេ ។ ការិយាល័យបានផ្តល់អ្នកជំនាញការច្បាប់មួយរូបដើម្បីជួយរៀបចំឯកសារសិក្សាវិភាគមួយ ដើម្បីពិនិត្យអំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមប្រឹក្សានេះ និងផ្តល់ជាអនុសាសន៏អំពីវិធានការសមស្របសំរាប់ធ្វើកំណែទម្រង់ក្រុមប្រឹក្សានេះ ។

៣៨. កាលពីខែមេសា ឆ្នាំ ២០០៣ ការិយាល័យបានចាប់ផ្តើមធ្វើការពិគ្រោះយោបល់ជាមួយគណៈមេធាវី អាជ្ញាធរពាក់ព័ន្ធនៃក្រសួងយុត្តិធមិ និងអង្គការក្រៅរដ្ឋាភិបាលទាំងឡាយដែលពាក់ព័ន្ធក្នុងការផ្តល់មេធាវីសំរាប់ការពារជនក្រីក្រ ដើម្បីពិនិត្យអំពីស្ថានភាពមេធាវីតំណាងនៅក្នុងប្រទេសកម្ពុជា ។ ការិយាល័យក៏បានចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវជាសាមញ្ញមួយផងដែរ អំពីមេធាវីតំណាងនៅក្នុងបណ្តាខេត្តចំនួន៤ នៅក្នុងប្រទេសកម្ពុជា ។ ដំណាក់កាលដំបូងបង្អស់ បានធ្វើការសិក្សាស្រាវជ្រាវឡើងនៅក្នុងតុលាការចំនួន៣ ដែលស្ថិតនៅក្នុងខេត្តមួយចំនួនដែលមានវត្តមានមេធាវី ការពារជនក្រីក្រ (ក្រុងព្រះសីហនុ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង) ហើយនិងនៅក្នុងខេត្តមួយទៀតដែល មិនមានវត្តមានមេធាវីការពារជនក្រីក្រ (ខេត្តព្រៃវែង) ។ បុគ្គលិកការិយាល័យបានពិនិត្យនៅក្នុងបញ្ជីរបស់តុលាការ ហើយបានកំណត់ពីចំនួនសរុបនៃករណីរឿង ដែលបានជំនុំជំរះក្នុងអំឡុងឆ្នាំ ២០០១ និងឆ្នាំ ២០០២ បានកត់ត្រាអំពីចំនួនករណីរឿងដែលមានមេធាវីតំណាង នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំនោះ ហើយបានបំបែកស្ថិតិនេះជាបទឧក្រិដ្ឋ បទមជ្ឈឹម ឬករណីរឿងរដ្ឋប្បវេណី និងទៅតាមប្រភេទករណីនីមួយ១ជាក់លាក់ ។ ក្នុងរឿង

រដ្ឋប្បវេណី ការិយាល័យបានធ្វើកំណត់អំពីភាគីមួយ ឬភាគីទាំងពីរមាន ឬគ្មានមេធាវីតំណាង ។ បុគ្គលិកការិយាល័យក៏បានធ្វើសម្ភាសន៍ជាលក្ខណៈពាក់កណ្តាលរចនាសម្ព័ន្ធជាមួយចៅក្រម ព្រះរាជអាជ្ញា និងជាមួយជនដែលពាក់ព័ន្ធនិងការផ្តល់មេធាវីការពារជនក្រីក្រ ។ ឯកសារសំរាប់ពិភាក្សាដំបូង នឹងត្រូវបានរៀបចំឡើងផ្អែកលើអង្គហេតុជាមូលដ្ឋាន ដែលបានរកឃើញតាមរយៈការសិក្សាស្រាវជ្រាវនេះ ហើយដែលត្រូវបានចែកផ្សាយនៅដើមឆ្នាំ២០០៤ ។ ការសិក្សានេះ មានគោលបំណងនិងរៀបរាប់អំពីសភាពការណ៍បច្ចុប្បន្នទាក់ទងនិងបញ្ហាមេធាវីតំណាងនៅក្នុងតុលាការ និងអំពីសិទ្ធិត្រូវមានជំនួយផ្នែកច្បាប់ក្នុងលក្ខណៈទូជាទៅ ដើម្បីធ្វើការប៉ាន់ប្រមាណពីសេចក្តីត្រូវការរបស់ប្រទេសកម្ពុជា ក្នុងការធានាសិទ្ធិដោះស្រាយរឿងក្តីតាមផ្លូវតុលាការសំរាប់ ប្រជាពលរដ្ឋកម្ពុជាភាគច្រើន ដែលមិនមានលទ្ធភាពអាចបង់ប្រាក់សំរាប់ជួលមេធាវីតំណាង និងការប្រឹក្សា យោបល់ខាងច្បាប់ ។ ការិយាល័យប្រចាំកម្ពុជាសង្ឃឹមថាបញ្ហានេះអាចជាមូលដ្ឋានមួយសំរាប់បង្កើតអោយមានគំរោងមេធាវីការពារជនក្រីក្រ ដើម្បីផ្តល់សេវាច្បាប់ជាមូលដ្ឋានដល់ជនក្រីក្រ ហើយដែលរដ្ឋអាចនិងជួយផ្តល់ជាមូលនិធិដល់គំរោងមេធាវីការពារជនក្រីក្រនេះដូចនៅបណ្តាប្រទេសដទៃទៀត ។

៣៩. ការិយាល័យក៏បានសហប្រតិបត្តិការជាមួយសាលាភូមិន្ទបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញា ដែលបានចាប់ផ្តើមដំណើរការកាលពីខែវិច្ឆិកា ឆ្នាំ២០០៣ ដើម្បីស្វែងយល់អោយបានច្បាស់អំពីថាតើការិយាល័យត្រូវធ្វើដូចម្តេចខ្លះដើម្បីជួយដល់សាលាអោយបានល្អក្នុងការធានា អោយមានការបញ្ចូលនូវមុខវិជ្ជាសិទ្ធិមនុស្សអោយបានគ្រប់សព្វទៅក្នុងកម្មវិធីសិក្សា ។ ការិយាល័យបានផ្តល់ឯកសារធនធានច្បាប់ បានការរៀបចំអោយលោកតំណាងពិសេសបានជួបធ្វើបឋកថាដល់និស្សិតចៅក្រម ហើយសង្ឃឹមថានឹងបានជួយបង្ហាត់បង្រៀននូវជំនាញផ្នែកសិទ្ធិមនុស្សនៅក្នុងកម្មវិធីសិក្សា នាដើមឆ្នាំ ២០០៤ ខាងមុខនេះ ។

## (ខ) ជំនួយឧបត្ថម្ភក្នុងកិច្ចដំណើរការធ្វើច្បាប់ : ការព្រាង និង អនុវត្តន៏ច្បាប់ ដើម្បីលើកស្ទួយ និង ការពារសិទ្ធិមនុស្ស

៤០. ការិយាល័យបានបន្តតាមដាន និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងបទបញ្ជាផ្សេងៗ ដើម្បីលើកស្ទួយការគោរពច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងដើម្បីធ្វើអោយគុណភាពបច្ចេកទេសនៃសេចក្តីព្រាងច្បាប់បានកាន់តែប្រសើរថែមទៀត ដោយផ្តោតការយកចិត្តទុកដាក់លើច្បាប់ទាំងឡាយណាដែលទាក់ទងដោយផ្ទាល់ទៅនឹងតួនាទីភារកិច្ចរបស់ការិយាល័យទៅនឹងបញ្ហាអាទិភាពជាទូទៅ ។ ច្បាប់ដែលមាន

សារៈប្រយោជន៍ជាពិសេស រួមមានច្បាប់ដែលទាក់ទងនិងការប្រឆាំងអំពើពុករលួយ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទ និងអនុក្រឹត្យស្តីពីដីធ្លី និងព្រៃឈើ ។ មន្ត្រីរបស់ការិយាល័យបានបន្តតាមដានអំពីការជឿនលឿនទៅមុខនៃដំណើរការក្នុងការរៀបចំក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ (ដែលបានរៀបចំឡើងដោយមានជំនួយពីអ្នកជំនាញការច្បាប់បារាំង) និងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី (ដែលបានរៀបចំព្រាងដោយមានជំនួយពីអ្នកជំនាញការច្បាប់ជប៉ុន) ក្រមទាំង នោះត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រី ។ ការិយាល័យបានកត់សំគាល់ពីការចាំបាច់ត្រូវធានាធ្វើយ៉ាងណាអោយមានភាពស្របគ្នា រវាងក្រមជាមូលដ្ឋានគ្រឹះទាំងនេះ និងច្បាប់ទាំងឡាយដែលកំពុងតែអនុម័តទាក់ទងនឹងការសុំចូលជាសមាជិកភាព នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ។

៤១.    សកម្មភាពអង្គការនីតិបញ្ញត្តិត្រូវបានផ្អាកទាំងស្រុង នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះដោយសារការខកខានក្នុងការបង្កើតរដ្ឋាភិបាលនៅក្រោយការបោះឆ្នោត ។ ទោះជាយ៉ាងណាក្តី ការិយា-ល័យនៅតែបន្តលើកស្ទួយអោយមានការចូលរួមអោយបានច្រើននៅក្នុងកិច្ចដំណើរការធ្វើច្បាប់ ការនេះបានលើកឡើងម្តងហើយម្តងទៀតជាច្រើនលើកច្រើនសារ ដើម្បីអោយឃើញពីសារៈសំខាន់ ប៉ុន្តែជារឿយៗ មិនបានអើពើពីសេចក្តីត្រូវការអោយមានការពិគ្រោះយោបល់ក្នុងកិច្ចដំណើរការព្រាងច្បាប់ និងដើម្បីអោយសាធារណៈជនជួយពិនិត្យពិច័យនៅមុនពេលយកច្បាប់ទៅអនុម័តនោះទេ ។ ការិយាល័យក៏បានគូសបញ្ជាក់ផងដែរ អំពីសេចក្តីត្រូវការចាំបាច់អោយច្បាប់បានដំណើរការទៅមុខដោយឆាប់រហ័សនិងការងាយស្រួលរក ។

## ឈ. ការិយាល័យប្រចាំតំបន់ក្នុងខេត្តបាត់ដំបង

៤២.    ការិយាល័យប្រចាំតំបន់នៅខេត្តបាត់ដំបងមានវិសាលភាពគ្របដណ្តប់លើខេត្តបាត់ដំបង បន្ទាយ-មានជ័យ និង ឧត្តរមានជ័យ ព្រមទាំងក្រុងប៉ៃលិនផង ធ្វើការនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យធំនៅទីក្រុងភ្នំពេញ ។ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មន្ត្រីរបស់ការិយាល័យបានពិនិត្យឃ្លាំមើលនិងស៊ើបអង្កេតចំពោះពាក្យបណ្តឹងស្តីពីការរំលោភសិទ្ធិមនុស្សទាក់ទងនឹងការបោះឆ្នោត ធ្វើអន្តរាគមន៍ជាប្រចាំទៅអាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាននានា ។ ការងារនេះបានធ្វើឡើងដោយសហការយ៉ាងជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាលនានា និងតាមរយៈទំនាក់ទំនងគ្នាជាមួយអង្គការឃ្លាំមើលការបោះឆ្នោត

ជាតិ និងអន្តរជាតិ ។ ការិយាល័យបានរក្សាទំនាក់ទំនងជាប្រចាំជាមួយអាជ្ញាធរខេត្ត តុលាការ នគរបាល និងយោធា នៅពេញរយៈពេលធ្វើរបាយការណ៍ ។

៤៣. ការិយាល័យបានស៊ើបអង្កេតករណីរឿងដែលរសើប ដែលទាក់ទងទៅនឹងការចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្សនៅក្នុងតំបន់ឆ្ងាយដាច់ស្រយ៉ាល ដែលក្រុមសិទ្ធិមនុស្សនៅមូលដ្ឋានលំបាកទៅដល់ ហើយនិងនៅក្នុងតំបន់ទាំងឡាយដែលមានការរំលោភសិទ្ធិមនុស្សជាទូទៅគ្រប់ទីកន្លែង ឬជាយថាក្រម ។ មន្ត្រីរបស់ការិយាល័យទាំងនោះបានធ្វើការឃ្លាំមើលជាប្រចាំនៅក្នុងស្រុកនានាដែលស្ថិតនៅក្នុងរយៈពេលអន្តរកាលដែលដោះស្រាយមិនបានដាច់ស្រេច ក្នុងការផ្ទេរប្រគល់របៀបគ្រប់គ្រងពីតាមបែបយោធាមកជាបែបស៊ីវិលវិញ ដោយធ្វើការផ្សារភ្ជាប់ការងារនេះទៅនិងការខិតខំប្រឹងប្រែងជំរុញការអប់រំ និងការហ្វឹកហ្វឺន ។

៤៤. ការិយាល័យប្រចាំកម្ពុជាក៏បានធ្វើការស៊ើបអង្កេត និងបានខិតខំប្រឹងប្រែងរួមគ្នាដើម្បីដោះស្រាយទំនាស់ទាក់ទងជំលោះលើធនធានធម្មជាតិ ដូចជាជំលោះដីធ្លីដែលអូសបន្លាយរយៈពេលជាយូរមកហើយនៅក្នុង ស្រុកកោះក្រឡ ហើយនិងជំលោះទាក់ទងនឹងសហគមន៍នេសាទព្រែកចាស់ដែលក្នុងនោះអ្នកតំណាងរបស់គេត្រូវប្រឈមមុខនិងការដាក់ពន្ធនាគារ និងត្រូវពិន័យជាប្រាក់បន្ទាប់ពីបានរឹបអូសឧបករណ៍នេសាទខុសច្បាប់ពីឈ្មួញម្នាក់ក្នុងមូលដ្ឋាន ។ បច្ចុប្បន្ន ករណីរឿងនេះកំពុងស្ថិតក្នុងសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ ។ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មន្ត្រីរបស់ការិយាល័យបានរៀបចំការហ្វឹកហ្វឺនដែលមានរយៈពេលមួយថ្ងៃជាច្រើនវគ្គស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ដល់អ្នកស្រុក និង អាជ្ញាធរមូលដ្ឋាន ជាពិសេសនៅក្នុងស្រុកទាំងឡាយដែលប្រជាពលរដ្ឋមានផលប៉ះពាល់ដោយសារជំលោះដីធ្លី ។

## ៣- កាតព្វកិច្ចក្នុងការធ្វើរបាយការណ៍អំពីសិទ្ធិមនុស្ស និង ក្នុងការអនុវត្តន៍អនុសាសន៍ធ្វើឡើងដោយស្ថាប័នត្រួតពិនិត្យការអនុវត្តសន្ធិសញ្ញា

៤៥. ប្រទេសកម្ពុជា គឺជាភាគីនៃលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិធំៗ ចំនួន ៦ ។ ការិយាល័យប្រចាំកម្ពុជាបានជួយឧបត្ថម្ភដល់រដ្ឋាភិបាល ក្នុងការរៀបចំព្រាងរបាយការណ៍ស្តីពីសន្ធិសញ្ញាផ្សេងៗ ចាប់តាំងពីឆ្នាំ១៩៩៤ មក ហើយបានជួយរៀបចំព្រាងគ្រប់របាយការណ៍ដំបូងៗទាំងអស់ ។ ចាប់តាំងពីខែសីហា ឆ្នាំ

២០០១ ការទទួលខុសត្រូវក្នុងការព្រាងរបាយការណ៍ភាគច្រើនត្រូវបានប្រគល់ទៅអោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាវិញ។ បច្ចុប្បន្ននេះ បុគ្គលិកគណៈកម្មាធិការដែលធ្វើរបាយការណ៍សន្ធិសញ្ញាចែកចេញជា២ អនុគណៈកម្មាធិការ ដើម្បីរៀបចំព្រាងរបាយការណ៍ដំបូងស្តីពីការអនុវត្តតាមកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយនិងរបាយការណ៍តាមកាលកំណត់សំរាប់ដាក់ជូនគណៈកម្មាធិការលុបបំបាត់គ្រប់រូបភាពនៃការរើសអើងពូជសាសន៍។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារទទួលបន្ទុកក្នុងការរៀបចំធ្វើរបាយការណ៍ស្តីពីអនុសញ្ញាស្តីពីសិទ្ធិកុមារ និងដើម្បីត្រួតពិនិត្យមើលអំពីការអនុវត្តអនុសញ្ញានេះ។ ក្រសួងកិច្ចការនារី និង អតីតយុទ្ធជនទទួលបន្ទុកក្នុងការរៀបចំរបាយការណ៍ស្តីពីអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW)។ របាយ-ការណ៍ដំបូងស្តីពីការអនុវត្តតាមអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលបានដាក់បញ្ចូលផងដែរនៅក្នុងរបាយការណ៍លើកទី២ និងទី៣ បច្ចុប្បន្ននេះកំពុងស្ថិតក្នុងដំណាក់កាលចុងក្រោយ ហើយសង្ឃឹមនឹងបានដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្សនៅមុនបំណាច់ឆ្នាំនេះ។

៤៦. នៅពេលដែលមិនមានក៏រិតស្មើគ្នាទៅនឹងឆ្នាំកន្លងទៅ ការិយាល័យប្រចាំកម្ពុជានឹងបន្តជួយក្នុងការរៀបចំរបាយការណ៍សំរាប់ដាក់ជូនស្ថាប័នត្រួតពិនិត្យការអនុវត្តសន្ធិសញ្ញា តាមរយៈការផ្តល់ជំនួយបច្ចេកទេស វគ្គបណ្តុះបណ្តាលជំនាញចំទិសដៅ និង ឯកសារពាក់ព័ន្ធនឹងឯកសារធនធានច្បាប់ ដើម្បីជួយដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្នុងការប្រមូលផ្តុំជាដំបូងនូវឯកសារធនធានច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងឯកសារស្តីពីបញ្ហាសិទ្ធិមនុស្សក្នុងប្រទេស។ ដោយធ្វើការជាមួយស្ថាប័នរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានាផងនោះ បច្ចុប្បន្ននេះ ការិយាល័យនឹងផ្តោតការយកចិត្តទុកដាក់លើការលើកស្ទួយ និងតាមដានដើម្បីធ្វើសេចក្តីសន្និដ្ឋានសរុបអំពីសេចក្តីសង្ខេបដែលធ្វើឡើងដោយស្ថាប័នសំរាប់ត្រួតពិនិត្យការអនុវត្តសន្ធិសញ្ញា។

៤៧. គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម នៅក្នុងសម័យប្រជុំលើកទី៣០ របស់ខ្លួនកាលពីខែមេសា-ឧសភា ឆ្នាំ ២០០៣ បានពិនិត្យពិចារណាលើរបាយការណ៍ដំបូងរបស់ប្រទេសកម្ពុជាស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬ ដែលត្រូវនាំអោយបាត់បង់តម្លៃជាមនុស្ស ដែលត្រូវដល់ពេលកំណត់កាលពីខែវិច្ឆិកា ឆ្នាំ១៩៩៣។ ក៏ប៉ុន្តែនៅពេលនោះ គណៈប្រតិភូតំណាងរដ្ឋាភិបាលពីទីក្រុងភ្នំពេញមិនមានវត្តមានដើម្បីឆ្លើយនិងសំណួររបស់គណៈកម្មាធិការនោះទេ។ គណៈកម្មាធិការបានធ្វើសេចក្តីសន្និដ្ឋាន និង

អនុសាសន៍ជាបណ្ដោះអាសន្នដោយស្នើសុំអោយរដ្ឋាភិបាលឆ្លើយតបវិញមុនបំណាច់ខែសីហា ឆ្នាំ២០០៣។ ការិយាល័យបានធ្វើការបកប្រែសេចក្ដីសន្និដ្ឋាន និងអនុសាសន៍ទាំងនេះជាភាសាខ្មែរ ហើយបានផ្ញើជូនស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល ក្នុងនោះបានផ្ញើជូនគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ប្រធាននាយកដ្ឋានព័ន្ធនាគារ និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ដោយមិនមានការឆ្លើយតបពីរដ្ឋាភិបាលមកវិញនោះ គណៈកម្មាធិការក៏បានអនុម័តសេចក្ដីសន្និដ្ឋាន និងអនុសាសន៍នេះជាស្ថាពរ នៅក្នុងសម័យប្រជុំលើកទី៣១ របស់ខ្លួនកាលពីខែវិច្ឆិកា ឆ្នាំ ២០០៣។

## ដ- ជំនួយផ្នែកអប់រំ និង បច្ចេកទេស និង កម្មវិធីពត៌មានសាធារណៈ

៤៨. ការិយាល័យប្រចាំកម្ពុជាធ្វើការរួមគ្នាជាមួយស្ថាប័នដទៃទៀត ដើម្បីបង្កើតបរិយាកាសងាយស្រួលមួយដើម្បីអោយអាចធ្វើការងារសិទ្ធិមនុស្សបាន រួមមានតាមរយៈការអប់រំដល់សាធារណៈជន និងការសម្រួលអោយមានការពិភាក្សា និងផ្លាស់ប្ដូរយោបល់គ្នា។ ឧទាហរណ៍ នៅក្នុងអំឡុងពេលបំពេញបេសកកម្មលើកទី១០ របស់លោកតំណាងពិសេស ការិយាល័យបានរៀបចំធ្វើជាកិច្ចពិភាក្សាតុមូលជាច្រើនលើក ដោយបានអញ្ជើញមន្ត្រីសំខាន់ៗរបស់រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលនានា និង ទីភ្នាក់ងារនៃបណ្ដាប្រទេសអ្នកផ្ដល់ជំនួយដើម្បីមកចូលរួមពិភាក្សាអំពីកំណែទម្រង់ផ្នែកប្រព័ន្ធយុត្តិធម៌ បញ្ហាសុខភាព និងបញ្ហាដីធ្លី។

៤៩. ការិយាល័យបានបន្តផ្ដល់ការបណ្ដុះបណ្ដាល ប្រឹក្សាយោបល់ផ្នែកច្បាប់ និង បច្ចេទេសដទៃទៀត ដល់អង្គការក្រៅរដ្ឋាភិបាលនានា និង អង្គការសហគមន៍នៅតាមមូលដ្ឋាន លើគ្រប់វិស័យនៃការងាររបស់ខ្លួន។

៥០. ការបោះពុម្ពផ្សាយឯកសារសិទ្ធិមនុស្ស ច្បាប់ និងឯកសារពត៌មានផ្សេងៗ បានបន្តធ្វើការចែកជូនដល់សាធារណៈជនជាទូទៅ អង្គការក្រៅរដ្ឋាភិបាលនានា និស្សិត និងមន្ត្រីរដ្ឋាភិបាល។ សេចក្ដីថ្លែងការណ៍ និង របាយការណ៍របស់ការិយាល័យ និង របស់លោកតំណាងពិសេស ព្រមទាំងសេចក្ដីសំរេចចិត្តរបស់មហាសន្និបាត និង គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ត្រូវបានបកប្រែជាភាសាខ្មែរ តាមទម្លាប់អនុវត្តន៏ជាទៀងដរាប។ បានបកប្រែជាលើកដំបូងនៃលិខិតុបករណ៍អន្តរសិទ្ធិមនុស្សអន្តរជាតិដែលបាន

ពិនិត្យឡើងវិញរួចហើយ ជាពិសេសទាក់ទងនឹងប្រទេសកម្ពុជា នឹងត្រូវបោះពុម្ពផ្សាយនៅដើមឆ្នាំ ២០០៤ ខាងមុខនេះ ។

៥១. បច្ចុប្បន្ននេះការិយាល័យប្រចាំកម្ពុជាបានបង្កើតទំព័រវេព (web page) ដើម្បីធ្វើការផ្សព្វផ្សាយ ពីរបាយការណ៍របស់លោកតំណាងពិសេស និង របស់ការិយាល័យ និងពត៌មាននានាស្តីពីប្រវត្តិសាវតា និង តួនាទីភារកិច្ចរបស់ការិយាល័យ និងរបស់លោកតំណាងពិសេស ដើម្បីអោយសាធារណៈទូទៅអាចមាន លទ្ធភាពប្រើប្រាស់បាន ។ បច្ចុប្បន្ននេះ ការិយាល័យកំពុងរៀបចំបន្ទប់ដាក់ឯកសារឡើងវិញ រួមទាំងការ រៀបចំទុកដាក់ឯកសារ និងការប្រើប្រាស់បច្ចេកទេសវិជ្ជាដោយមាន ទូរទស្សន៍ ម៉ាស៊ីនចាក់វីឌីអូ និងការ ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតមានកំណត់ ។

៥២. ការិយាល័យបានធ្វើទំនាក់ទំនងគ្នាជាប្រចាំ ជាមួយប្រព័ន្ធសារពតិមាននៅក្នុងប្រទេសកម្ពុជាទាំង សារពតិមានក្នុងស្រុកជាភាសារខ្មែរ ទាំងជាភាសារអង់គ្លេស និងសេវាកម្មខាងវិទ្យុ ។

## ថ- កិច្ចសហប្រតិបត្តិការ និង ការសម្របសំរួលជាមួយប្រព័ន្ធអង្គការ សហប្រជាជាតិ ប្រទេសអ្នកផ្តល់ជំនួយ និងសហគមន៍អ្នកការទូត

៥៣. ការិយាល័យប្រចាំកម្ពុជា គឺជាសមាជិកមួយនៃក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស (UNCT) ហើយបានផ្តល់ជូនសមាជិកទាំងអស់របស់ UNCT ធនាគារពិភពលោក និងផ្នែកពាក់ព័ន្ធដទៃ ទៀតនូវពតិមានស្តីពីការដាក់បញ្ចូលបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និង ក្នុងគោលដៅអភិវឌ្ឍន៍សហសវត្សស្របតាមសេចក្តីព្រាងគោលការណ៍ណែនាំអំពីប្រធានបទនេះ របស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ។

៥៤. កាលពីខែ កញ្ញា ឆ្នាំ ២០០៣ ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស (UNCT) បានចាត់ទុក សិទ្ធិមនុស្សជាបញ្ហាមួយដែលត្រូវយកចិត្តទុកដាក់រួមគ្នា ហើយការិយាល័យកំពុងខិតខំដាក់បញ្ចូលសិទ្ធិ មនុស្សអោយបានពេញលេញថែមទៀត នៅក្នុងការងាររបស់ UNCT និងទីភ្នាក់ងារជាសមាជិករបស់ ខ្លួន ។ ការិយាល័យក៏បានរួមចំណែកក្នុងការត្រួតពិនិត្យឡើងវិញសំរាប់ពាក់កណ្តាលអាណត្តិ លើក្របខ័ណ្ឌ ជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ និង ក្នុងស្ថាប័នប្រឹក្សាយោបល់លើគោលដៅអភិវឌ្ឍន៍

សហសវត្សដើម្បីនឹងលើកកំពស់សិទ្ធិមនុស្សអោយទៅជាស្នូលសំខាន់ និង ផ្អែកតាមគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋានធ្វើជាវិធីសំរាប់ដោះស្រាយ ។ បច្ចុប្បន្ននេះ មានមន្ត្រីរបស់ការិយាល័យមួយរូបកំពុងធ្វើការដោយមានការលះបង់ខ្ពស់ចំពោះភារកិច្ចទាំងនេះ ។

៩៥. ការិយាល័យបានធ្វើសេចក្តីរាយការណ៍ត្រួសៗយ៉ាងទៀងទាត់ ជូនអ្នកការទូតប្រចាំនៅក្នុងប្រទេស និងអ្នកការទូតដែលមកទស្សនកិច្ច និង អង្គការអន្តរជាតិ ហើយបានរៀបចំធ្វើរបាយការណ៍ជាប្រចាំដើម្បីដាក់ជូនទីស្នាក់ការកណ្តាលនៃការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សដើម្បីបំពេញតាមការតម្រូវក្នុងការធ្វើរបាយការណ៍ នៃប្រព័ន្ធអង្គការសហប្រជាជាតិ ។ ការិយាល័យក៏បានផ្តល់របាយការណ៍ជូនអ្នកសម្របសំរួលប្រចាំតំបន់របស់ អ.ស.ប និង ប្រទេសអ្នកផ្តល់ជំនួយផងដែរតាមការចាំបាច់ ។

## III- បុគ្គលិកការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និងស្ថានភាពហិរញ្ញវត្ថុនៃមូលនិធិឧបត្ថម្ភដោយស្ម័គចិត្តរបស់អង្គការសហប្រជាជាតិ សំរាប់កម្មវិធីអប់រំសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា

៩៦. ការិយាល័យបានអនុវត្តសកម្មភាពរបស់ខ្លួន តាមរយៈការិយាល័យកណ្តាលប្រចាំនៅទីក្រុងភ្នំពេញ ការិយាល័យតំបន់នៅក្នុងខេត្តបាត់ដំបង ការិយាល័យបោះឆ្នោតក្នុងខេត្តកំពង់ចាម និងការិយា- ល័យតូចៗប្រចាំនៅតុលាការក្រុងភ្នំពេញ និងតុលាការក្រុងព្រះសីហនុដែលបានបិទទ្វារកាលពីខែកញ្ញាកន្លងទៅនេះ ។ រចនាសម្ព័ន្ធសំរាប់គ្រប់គ្រងរួមមាន ការិយាល័យនាយក អង្គភាពផ្នែករដ្ឋបាល អង្គភាពការពារ និងអភិវឌ្ឍន៏គោលនយោបាយ អង្គភាពផ្នែកជំនួយការច្បាប់ អង្គភាពផ្នែកអប់រំបណ្តុះបណ្តាល និងពតិមាន ។ នៅពេលសរសេររបាយការណ៍នេះ ការិយាល័យមានបុគ្គលិកក្នុងស្រុកចំនួន ៣២ នាក់ និងបុគ្គលិកអន្តរជាតិចំនួន៨ នាក់ ។

៩៧. ការិយាល័យនាយកមានភារកិច្ចទទួលខុសត្រូវអំពីគោលនយោបាយ និង ការចាត់ចែងគ្រប់គ្រងរួមទាំងការសម្របសំរួលការងារសំរាប់ជួយគាំទ្រដល់តំណាងពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប ចូលរួមនៅក្នុងប្រព័ន្ធរបស់អង្គការសហប្រជាជាតិ ធ្វើការជាមួយទីភ្នាក់ងារអន្តរជាតិនានា និង អង្គការក្រៅរដ្ឋាភិបាលដទៃទៀត និងទំនាក់ទំនងខាងក្រៅ និងជាមួយបណ្តាប្រទេសអ្នកផ្តល់ជំនួយ ។

៥៨. អង្គភាពផ្នែករដ្ឋបាលផ្តល់សេវាផ្នែកបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ដល់ការិយាល័យ និងសម្របសំរួលមធ្យោបាយដឹកជញ្ជូន និងភស្តុភា ។ អង្គភាពរដ្ឋបាលក៏មានភារកិច្ចទទួលខុសត្រូវខាងការគ្រប់គ្រងពតិមានផងដែរ ។

៥៩. អង្គភាពការពារ និង អភិវឌ្ឍន៍គោលនយោបាយ មានភារកិច្ចទទួលខុសត្រូវរៀបចំកម្មវិធីសំរាប់ការបោះឆ្នោត ស៊ើបអង្កេតពាក្យបណ្តឹងទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស រៀបចំរបាយការណ៍តាមប្រភេទរឿង និង ធ្វើការជាមួយអង្គភាពដទៃទៀតលើបញ្ហាទាក់ទងនឹងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ និង បញ្ហានិទណ្ឌភាព ។

៦០. អង្គភាពផ្នែកជំនួយការច្បាប់ មានភារកិច្ចទទួលខុសត្រូវក្នុងការជួយដល់កិច្ចដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងធ្វើការជាមួយតុលាការ ដើម្បីដោះស្រាយបញ្ហាកង្វះខាតផ្សេងៗ ក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ។ អង្គភាពធ្វើការជាមួយអ្នកវិជ្ជាជីវៈច្បាប់ និងជួយផ្តល់យោបល់នៅលើសេចក្តីព្រាងច្បាប់ដែលជ្រើសយកមួយចំនួន ដើម្បីធានាអោយមានការគោរព និង អនុវត្តអោយបានត្រឹមត្រូវតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងឡាយដែលប្រទេសកម្ពុជាជាហត្ថលេខី ។

៦១. អង្គភាពផ្នែកអប់រំបណ្តុះបណ្តាល និងពតិមាន មានភារកិច្ចទទួលខុសត្រូវអប់រំ ផ្សព្វផ្សាយបណ្តុះបណ្តាលដល់សាធារណជន និងតស៊ូមតិ ដើម្បីលើកស្ទួយដល់ការអនុវត្តសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ អង្គភាពនេះបានធ្វើការផងដែរជាមួយរដ្ឋាភិបាល ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស (UNCT) និងទីភ្នាក់ងារនៃអង្គការអន្តររដ្ឋាភិបាលស្តីពីការអភិវឌ្ឍន៍ដោយផ្អែកតាមគោលការណ៍សិទ្ធិមនុស្សសំរាប់ការដោះស្រាយ ។

៦២. អង្គការសហប្រជាជាតិបានផ្តល់ថវិការរបស់ខ្លួនប្រចាំឆ្នាំសំរាប់រាល់ការចំណាយនានាក្នុងការប្រតិបត្តិការការងាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា រួមទាំងសំរាប់ចំណាយលើប្រាក់បៀវត្សបុគ្គលិកជំនាញអន្តរជាតិចំនួន៧ រូប និងបុគ្គលិកក្នុងស្រុកចំនួន១៦ រូបទៀត ។ វិភាគទានស្ម័គ្រចិត្តសំរាប់មូលនិធិរបស់អង្គការសហប្រជាជាតិសំរាប់កម្មវិធីអប់រំសិទ្ធិមនុស្សនៅកម្ពុជា បានផ្តល់សំរាប់រាល់ការចំណាយដទៃទៀត (រួមមានប្រាក់បៀវត្សសំរាប់បុគ្គលិក

ដែលមិនស្ថិតក្នុងក្រមខ័ណ្ឌថវិកាប្រចាំឆ្នាំ) ។ មូលនិធិឧបត្ថម្ភដោយស្ម័គ្រចិត្តគ្រប់គ្រងដោយការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ។

End.